# ដាវីន
## ខុសត្រង់ណា?

ដោយវេជ្ជបណ្ឌិត ចន ស៊ី សាន់ហ្វដ

By John C. Sanford, Ph.D.

បកប្រែនិងកែសម្រួលដោយលោក ចេ ឌី ក្រោលី

Translated and Adapted by J.D. Crowley

**ដាវីនខុសត្រង់ណា?**

**What Darwin Got Wrong**

Copyright ©2023 John C. Sanford, all rights reserved
Translated and Adapted for Khmer by J.D. Crowley
jamesdcrowley@gmail.com
Khmer translation copyright ©2023 EMU International

All photographs are public domain or used with permission.

Special thanks to Mr. Nget Sarith and Dr. Sann Mayura.

Other books by John C. Sanford Ph.D. at fmsfound.org:

- *Genetic Entropy*
- *Contested Bones*
- *The Sexual Holocaust* (free PDF at sexualholocaust.org)
- *Biological Information – New Perspectives* (Proceedings of the 2011 Symposium at Cornell University)

# មាតិកា

លំនាំដើម

១. លោក ដាវីនខុសអំពីព្រះជាម្ចាស់.......................៨

២. លោក ដាវីនខុសអំពីវិទ្យាសាស្ត្រ.....................១២

៣. លោក ដាវីនខុសអំពីភូគព្ភសាស្ត្រ (ផែនដីវិទ្យា) ...១៨

៤. លោក ដាវីនខុសអំពីហ្វូស៊ីល.........................២៦

៥. លោក ដាវីនខុសអំពីដើមឈើវិវត្តន៍................៣៧

៦. លោក ដាវីនខុសអំពីកោសិកា និងជីវិត.............៤៨

៧. លោក ដាវីនខុសអំពីជម្រើសដោយធម្មជាតិ.......៦៣

៨. ជំពូកបន្ថែម៖ ជម្រើសដោយធម្មជាតិមិនអាចទប់ស្កាត់ការរេចរឹលបន្តិចម្តងៗក្នុងប្រព័ន្ធហ្សែនទេ....៧៥

ឧបសម្ពន្ធ ១៖ លោក ដាវីនខុសអំពីជាតិសាសន៍ ......៨៨

ឧបសម្ពន្ធ ២៖ What Darwin Got Wrong (English) ..៩៧



## អ្នកនិពន្ធ៖
## វេជ្ជបណ្ឌិត ចន ស៊ី សាន់ហ្វដ

វេជ្ជបណ្ឌិត ចន ស៊ី សាន់ហ្វដ ( John C. Sanford) បានធ្វើជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Cornell (នៅរដ្ឋញូវយ៉ក) អស់រយៈពេលជាង២៥ឆ្នាំ។ និក្ខេបទបណ្ឌិតរបស់គាត់ គឺអំពីការបង្កាត់ពូជរុក្ខជាតិ និងហ្សែនរុក្ខជាតិ។ លោក ចនត្រូវបានបោះពុម្ពផ្សាយអត្ថបទនិងសៀវភៅវិទ្យាសាស្ត្រជាង ៨០ ហើយបានទទួលប៉ាតង់ជាង ៣០ពីរដ្ឋាភិបាល។ ការរួមចំណែកផ្នែកវិទ្យាសាស្ត្រដ៏សំខាន់បំផុតរបស់គាត់ ពាក់ព័ន្ធនឹងការច្នៃប្រឌិតចំនួនបីគឺ ដំណើរការជីវសាស្ត្រ («កាំភ្លើងហ្សែន») pathogen-derived resistance, and genetic immunization។ ភាគរយដ៏ច្រើននៃដំណាំប្តូរហ្សែនដែលដាំដុះនៅលើពិភពលោកសព្វថ្ងៃនេះ ត្រូវបានកែច្នៃហ្សែនដោយប្រើបច្ចេកវិទ្យា «កាំភ្លើងហ្សែន» ដែលបង្កើតឡើងដោយលោកចន និងអ្នកសហការជាមួយគាត់។





***ឆ្វេង៖** វេជ្ជបណ្ឌិត ចន ស៊ី សាន់ហ្វដ ជាមួយនឹងកាំភ្លើងហ្សែន (Biolistic)*
***ស្តាំ៖** កាំភ្លើងហ្សែន (Biolistic) ជាការច្នៃប្រឌិតដ៏សំខាន់បំផុតមួយក្នុងប្រវត្តិសាស្ត្រកសិកម្ម) នៅ National Museum of American History, Smithsonian Institute, Washington, D.C.*

# The Author:
# John C. Sanford, Ph.D.



Dr. John C. Sanford was a professor at Cornell University (New York) for more than 25 years. His Ph.D. was in plant breeding and plant genetics. While a professor at Cornell, John trained graduate students and conducted genetic research at the New York State Agricultural Experiment Station in Geneva, New York. During this time, John bred new crop varieties using conventional breeding and then became heavily involved in the newly-emerging field of plant genetic engineering. John has published over 80 scientific publications and has been granted over 30 patents. His most significant scientific contributions involve three inventions, the Biolistic ("gene gun") process, pathogen-derived resistance, and genetic immunization. A large fraction of the transgenic crops (in terms of numbers and acreage) grown in the world today were engineered using the gene gun technology developed by John and his collaborators.





***Left:*** *Dr. John Sanford with an early prototype of a gene gun.*
***Right:*** *The Biolistic Gene Gun, a groundbreaking invention in the history of agriculture, at the National Museum of American History, Smithsonian Institute, Washington, D. C.*

# លំនាំដើម

ហេតុអ្វីបានជាវាមានសារៈសំខាន់ខ្ពស់បំផុត ដែលលោក ឆាលស៍ ដាវីន (Charles Darwin) មានទស្សនៈខុស? មនុស្សទាំងអស់តែងតែមានកំហុសម្តងម្កាល។ បើសិនជាអ្នកក្រឡេកមើលតួអង្គណាមួយក្នុងប្រវត្តិសាស្រ្ត នោះអ្នកអាចរកឃើញកំហុស។ ហេតុអ្វីបានជាវាសំខាន់បើលោក ឆាលស៍ ដាវីនមានកំហុស? ពីព្រោះបុរសម្នាក់នេះ ដែលហាក់ដូចជាសាមញ្ញ បានជះឥទ្ធិពលយ៉ាងខ្លាំង ទាំងផ្នែកវិទ្យាសាស្រ្ត និងផ្នែកសាសនា។ គាត់បានផ្លាស់ប្តូរពិភពលោកយ៉ាងជ្រាលជ្រៅ ហើយគំនិតរបស់គាត់បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គម និងសីលធម៌។ ពិភពលោកដែលយើងរស់នៅសព្វថ្ងៃ ត្រូវបានរៀបចំឡើងដោយទស្សនៈ ដែលមកពីគាត់។ ដូច្នេះ អ្នកឃើញថាប្រសិនបើលោក ដាវីនគិតខុស វាជាបញ្ហាធំបំផុត ដែលផ្លាស់ប្តូរផែនដី។

ហើយខ្ញុំជឿថា គាត់ខុសមែន។ យើងអាចបង្ហាញថា លោក ដារីនមានកំហុសយ៉ាងធ្ងន់ធ្ងរ ចំពោះបញ្ហាសំខាន់ៗ ទាំងផ្នែកវិទ្យាសាស្ត្រ និងផ្នែកព្រលឹងវិញ្ញាណ។ ខ្ញុំគ្រាន់តែរៀបរាប់អំពីកំហុស៧យ៉ាងរបស់លោក ដារីន ដែលខ្ញុំជឿថា ធំជាងគេ។

១. លោក ដារីនខុសអំពីព្រះជាម្ចាស់
២. លោក ដារីនខុសអំពីវិទ្យាសាស្ត្រ
៣. លោក ដារីនខុសអំពីភូគព្ភសាស្ត្រ (ផែនដីវិទ្យា)
៤. លោក ដារីនខុសអំពីហ្វូស៊ីល
៥. លោក ដារីនខុសអំពីជីវិតរុក្ខជាតិ (ដើមជីវិត)
៦. លោក ដារីនខុសអំពីកោសិកា និងជីវិត
៧. លោក ដារីនខុសអំពីជម្រើសដោយធម្មជាតិ

មនុស្សភាគច្រើននៅសាកលវិទ្យាល័យជឿថា លោក ដារីននិយាយត្រូវទាំង៧ចំណុចនេះ ប៉ុន្តែខ្ញុំនឹងបង្ហាញអ្នកថា គាត់មិនត្រូវទេ។



# ១

# លោក ដាវីនខុសអំពីព្រះជាម្ចាស់

សំខាន់បំផុត គឺលោក ដាវីនខុសអំពីព្រះជាម្ចាស់។ យើងឃើញនៅក្នុងរូបខាងលើនេះ ដែលលោក ដាវីនកំពុងតែបែរខ្នងដាក់ឈើឆ្កាង ហើយដើរចូលទៅក្នុងទីងងឹត។ នេះគឺជាកំហុសដ៏ធ្ងន់ធ្ងរបំផុត ដែលមនុស្សអាចធ្វើបាន។ អ្នកណាក៏ដោយដែលធ្វើតាមជម្រើសនេះ នោះនឹងក្លាយជាមនុស្សល្ងីល្ងើ ទោះបីគាត់ឆ្លាតដូច លោក អាល់បឺត អាញស្តាញក៏ដោយ សៀវភៅនេះភាគច្រើន និយាយអំពីវិទ្យាសាស្រ្ត ប៉ុន្តែខ្ញុំត្រូវចាប់ផ្តើម និងបញ្ចប់ដោយចំណុចសំខាន់នេះ៖ លោក ដាវីនខុសអំពីព្រះជាម្ចាស់។ ជីវប្រវត្តិរបស់គាត់បានបង្ហាញយ៉ាងច្បាស់ថា គាត់បានបដិសេធ

ព្រះគម្ពីរ ហើយមានចេតនាបដិសេធព្រះគ្រីស្ទដែរ។ នោះពិតជាកំហុសដ៏ធំមួយ។ ព្រះគម្ពីរ រ៉ូម ១:២២ មានបន្ទូលអំពីមនុស្សដែលបដិសេធព្រះថា «គេអួតខ្លួនថា មានប្រាជ្ញា បានជាគេត្រឡប់ទៅជាល្ងង់ល្ងើវិញ»។

មនុស្សអាចនិយាយមកខ្ញុំថា «តើអ្នកជាអ្នកណាដែលហ៊ានថ្កោលទោសលោក ដាវីន?» តាមពិត ខ្ញុំមិនអាចថ្កោលគាត់បានឡើយ។ ខ្ញុំបានសិក្សាពីលោក ដាវីនជាច្រើនឆ្នាំមកហើយ ហើយនៅពេលដែលខ្ញុំបានអានអំពីជីវិតគាត់ នោះខ្ញុំនឹកចាំថា កាលពីខ្ញុំនៅវ័យយុវជន ខ្ញុំក៏ដូចជាលោក ដាវីនអញ្ចឹងដែរ។ តាមពិតទៅខ្ញុំជាអ្នកដែលជឿថា គ្មានព្រះសោះ ហើយខ្ញុំបានឯកភាពទាំងស្រុង ជាមួយទ្រឹស្តីវិវត្តន៍របស់លោក ដាវីនទៀត។ ដូច្នេះកុំគិតថា ខ្ញុំកំពុងអះអាងថា ខ្ញុំល្អជាងលោក ដាវីននោះឡើយ។ ខ្ញុំក៏បានធ្វើខុសដូចដែលគាត់បានធ្វើដែរ គ្រប់ចំណុចទាំងអស់។

## លោក ដាវីនបានដើរតាមជំនឿ
## ដ៏ពេញនិយមនៅជំនាន់គាត់

មនុស្សគិតថា លោក ដាវីនគឺជាមនុស្សបដិវត្តន៍ម្នាក់ ដែលបានផ្លាស់ប្តូរពិភពលោក ប៉ុន្តែតាមពិតគាត់ធ្វើតាមជំនឿដ៏

ពេញនិយម នៅជំនាន់គាត់។ តើអ្វីទៅជាជំនឿដ៏ពេញនិយមនៅពេលលោក ដាវីនធំឡើង? ទស្សនវិជ្ជានៃសម័យ Enlightenment (សម័យកាលយល់ដឹង ១៦៨៧–១៧៨៩) បានរីកដុះដាលរួចទៅហើយ នៅពេលដែលគាត់នៅក្មេង ហើយគាត់បានធំឡើងនៅក្នុងបរិយាកាសមួយ ដែលមានការសង្ស័យយ៉ាងខ្លាំង ចំពោះជំនឿប្រពៃណី។ វត្ថុនិយម ជាជំនឿដែលជឿថា មានតែវត្ថុប៉ុណ្ណោះ គ្មានអ្វីខាងព្រលឹងវិញ្ញាណទេ គឺមានប្រជាប្រិយភាពរួចទៅហើយ នៅក្នុងជំនាន់របស់គាត់នោះ។ សូម្បីតែនៅក្នុងគ្រួសាររបស់លោក ដាវីនផ្ទាល់ ក៏ជីតារបស់គាត់ល្បីល្បាញខាងបង្រៀនទ្រឹស្តីវិវត្តន៍ដែរ។ មនុស្សជាច្រើនគិតថា ទ្រឹស្តីវិវត្តន៍បានចាប់ផ្តើម ជាមួយលោក ឆាលស៍ ដាវីន។ តែមិនពិតទេ។ នៅពេលលោក ដាវីនចូលមហាវិទ្យាល័យ ទ្រឹស្តីវិវត្តន៍បានពេញនិយមរួចទៅហើយ។ ក្រុមជំនុំជាច្រើននៅសម័យលោក ដាវីន បានចាប់ផ្តើមជឿលើយុគសម័យភូគព្ភសាស្រ្តដ៏យូរលង់រួចមកហើយ និងបដិសេធនូវលទ្ធិនៃការធ្លាក់ចុះរបស់អ័ដាម និងអេវ៉ា។ ការពឹងផ្អែកលើការបើកសម្តែងរបស់ព្រះនៅក្នុងព្រះគម្ពីរត្រូវបានវាយប្រហារ ហើយជំនួសមកវិញ ដោយ

ការពឹងផ្អែកលើសមត្ថភាពនៃហេតុផលរបស់មនុស្សក្នុងការស្វែងរកការពិត។

លោក ដាវីនខ្លួនឯងបានបន្ទោសព្រះជាម្ចាស់ចំពោះអំពើអាក្រក់ដែលមាននៅក្នុងពិភពលោក។ គាត់ជឿថាពិភពលោកមានអាយុកាលរាប់រយលានឆ្នាំមកហើយ ហើយពេលវេលានោះ គឺពោរពេញដោយសេចក្តីស្លាប់ និងការឈឺចាប់។ គាត់បានលើកហេតុផលថា ដោយសារចំនួនដ៏ច្រើននៃសេចក្តីស្លាប់ ការរងទុក្ខវេទនា និងអំពើអាក្រក់ (គឺជាផ្នែកចាំបាច់នៃការវិវត្តន៍) ដូច្នេះ ព្រះដែលបានរចនាពិភពលោកឡើង គឺជាអ្នកដែលបានបង្កើតអំពើអាក្រក់នោះមក។ លោក ដាវីនមិនអាចទទួលយកព្រះដែលទទួលខុសត្រូវលើអំពើអាក្រក់បានទេ។ ដូច្នេះ មុននឹងខ្ញុំនិយាយអំពីកំហុសវិទ្យាសាស្រ្តរបស់លោក ដាវីន ខ្ញុំចង់បញ្ជាក់ថា កំហុសធំបំផុតរបស់លោក ដាវីន គឺការបែរចេញពីព្រះជាម្ចាស់។ នោះក៏ជាកំហុសធំបំផុតដែលយើងទាំងអស់គ្នាអាចធ្វើដែរ។




# ២

# លោក ដាវីនខុសអំពីវិទ្យាសាស្ត្រ

នៅក្នុងរូបភាពខាងលើ យើងឃើញមានរូបចម្លាក់ដ៏ល្បីល្បាញមួយដែលមានឈ្មោះថា «អ្នកគិត» ប៉ុន្តែត្រូវបានដាក់មុខលោក ដាវីនជំនួសវិញ។ សំណួរសួរថា តើលោក ដាវីនជាអ្នកវិទ្យាសាស្ត្រ ឬជាទស្សនវិទូ? ជាធម្មតាគាត់ត្រូវបានគេចាត់ទុកថា ជាអ្នកវិទ្យាសាស្ត្រដ៏អស្ចារ្យម្នាក់ក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែប្រសិនបើអ្នកអានស្នាដៃរបស់គាត់ និងការរៀបរាប់អំពីជីវិតរបស់គាត់ អ្នកនឹងយល់ឃើញថា តាមពិតគាត់ជាទស្សនវិទូទេ។ គាត់បានប្ដេជ្ញាចិត្តទាំងស្រុង ចំពោះទស្សនវិជ្ជាដែលគេហៅថា

ធម្មជាតិនិយម ដែលបង្រៀនថា អ្វីៗទាំងអស់ដែលយើងឃើញ និងស្គាល់ បានមកពីដំណើរការធម្មជាតិ ដោយគ្មានការអន្តរាគមពីព្រះជាម្ចាស់ឡើយ។

## លោក ដាវីនមិនមែនជាអ្នកវិទ្យាសាស្ត្រ ដែលធ្វើការពិសោធន៍នោះទេ

លោក ដាវីនមានសញ្ញាបត្រមហាវិទ្យាល័យតែមួយគត់ គឺផ្នែកទេវសាស្ត្រ។ គាត់បានសិក្សាអំពីទេវសាស្ត្រ ព្រោះគាត់គិតថា ការសិក្សានោះនឹងជួយគាត់ឈានទៅមុខក្នុងអាជីពរបស់គាត់។ គាត់មិនមានសញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ហើយមិនមែនជាអ្នកវិទ្យាសាស្ត្រដែលធ្វើការពិសោធន៍ឡើយ។ គាត់បានធ្វើការសង្កេតដ៏អស្ចារ្យមួយចំនួនអំពីធម្មជាតិ ជាពិសេសក្នុងអំឡុងពេលធ្វើដំណើរដ៏ល្បីល្បាញ តាមកប៉ាល់ដែលមានឈ្មោះថា អេចអ៊ឹម អេស ប៊ីហ្គល (H.M.S. *Beagle*)។ ប៉ុន្តែចាប់ពីពេលធ្វើដំណើរនោះរហូតដល់គាត់ចាស់ គាត់មិនបានធ្វើពិសោធន៍ខាងវិទ្យាសាស្ត្រអ្វីឡើយ។ យើងហៅគាត់ថា «អ្នកវិទ្យាសាស្ត្រសាឡុង» ដែលស្នាក់នៅក្នុងផ្ទះរបស់គាត់ ហើយបានសរសេរអំពីគំនិតរបស់គាត់ អំពីការវិវត្តន៍ និងជម្រើសដោយធម្មជាតិ។ គាត់មិនបានធ្វើការ

ពិសោធន៍ដូចអ្នកវិទ្យាសាស្ត្រដទៃទៀតនៅសម័យរបស់គាត់នោះទេ។

ក្នុងការបង្កើតគំនិតរបស់គាត់ លោក ដាវីនបានប្រើវិធីសាស្ត្រពីរយ៉ាង គឺ ១) ការនិទានរឿង និង ២) ការប្រើព្រឹត្តិការណ៍តូច ដើម្បីធ្វើជាភស្តុតាងអំពីព្រឹត្តិការណ៍ធំ (extrapolation)។ វិធីសាស្ត្រនៃការវែកញែកដែលគាត់ចូលចិត្តជាងគេ គឺ ទី២នោះ។ គាត់គិតថា ប្រសិនបើយើងឃើញសត្វមួយ មានការផ្លាស់ប្តូរតិចតួច (តាមរយៈជម្រើសដោយធម្មជាតិ) នោះសត្វមួយប្រភេទអាចផ្លាស់ប្តូរ ទៅជាប្រភេទសត្វថ្មីទាំងស្រុង តាមរយៈជំហានតូចៗ រាប់លានជំហាន។ ត្រីអាចផ្លាស់ប្តូរទៅជាសត្វល្មូន និងសត្វល្មូនទៅជាបក្សីវិញ!

គាត់ក៏ពឹងផ្អែកយ៉ាងខ្លាំងទៅលើការនិទានរឿង ពោលគឺបង្កើតរឿងអំពីរបៀបដែលគាត់ស្មានថា ប្រភេទសត្វមួយអាចផ្លាស់ប្តូរទៅជាប្រភេទមួយទៀត។ នៅក្នុងវិទ្យាសាស្ត្រពិត រឿងនិទានមិនមែនជាភស្តុតាងទេ។ ប៉ុន្តែនៅក្នុងវិទ្យាសាស្ត្រវិវត្តន៍ ប្រសិនបើអ្នកអាចប្រាប់រឿងនិទាន ឬការស្មានណាមួយ ដែលស្តាប់ទៅសមហេតុផល នោះវាល្អគ្រប់គ្រាន់ហើយ។

## លោក ដារីន មិនបានប្រើវិធីសាស្ត្រវិទ្យាសាស្ត្រទេ

លោក ដារីនមិនបានធ្វើពិសោធន៍ទ្រឹស្ដីរបស់គាត់ដោយប្រើវិធីសាស្ត្រវិទ្យាសាស្ត្រទេ។ គាត់បានធ្វើអំណះអំណាង និងការពារចំពោះគំនិតរបស់គាត់ ប៉ុន្តែមិនមែនដោយប្រើវិធីសាស្ត្រវិទ្យាសាស្ត្រទេ។ សៀវភៅរបស់គាត់គ្មានសមីការគណិតវិទ្យា និងគ្មានភស្តុតាងដែលសមហេតុផលជាផ្លូវការឡើយ (គ្មាន«អាគុយម៉ង់វិទ្យាសាស្ត្រ» ឬការវែកញែក)។ គាត់បានការពារគំនិតរបស់គាត់ដូចជាទស្សនវិទូ មិនមែនដូចជាអ្នកវិទ្យាសាស្ត្រទេ ព្រោះតាមពិតគាត់ជាទស្សនវិទូ។

## តើវិធីសាស្ត្រវិទ្យាសាស្ត្រគឺជាអ្វី?

**១. មានគំនិត ឬសំណួរ (ការប៉ាន់ស្មាន)៖** ដំណើរការវិទ្យាសាស្ត្រចាប់ផ្ដើមដោយគំនិត ឬការប៉ាន់ស្មានមួយ។ (ត្រូវហើយ អ្នកវិទ្យាសាស្ត្រត្រូវបានអនុញ្ញាតឲ្យប៉ាន់ស្មានដែរ ប៉ុន្តែ បើគេមិនបន្តជំហានទៀត នោះការប៉ាន់ស្មានមិនមែនជាវិទ្យាសាស្ត្រឡើយ)។

**២. បង្កើតសម្មតិកម្ម៖** បន្ទាប់ពីបង្កើតគំនិតមួយ អ្នកវិទ្យាសាស្ត្រត្រូវបង្ខំខ្លួន ដើម្បីសង្ខេបគំនិតនោះ ទៅជា

ប្រយោគមួយ ដែលអាចធ្វើការពិសោធន៍ ដើម្បីដឹងថា ពិត ឬមិនពិត។ ប្រយោគនេះ គេហៅថា សម្មតិកម្ម។

**៣. ធ្វើពិសោធន៍៖** បន្ទាប់មកអ្នកវិទ្យាសាស្ត្រត្រូវធ្វើពិសោធន៍ ដើម្បីសាកល្បងថា សម្មតិកម្មនោះជាការពិត ឬមិនពិត។ អ្នកវិទ្យាសាស្ត្រដទៃទៀតក៏អាចធ្វើការពិសោធន៍ដដែលនោះបានដែរ ដើម្បីបញ្ជាក់ថាសម្មតិកម្មនោះពិត ឬមិនពិត។

**៤. ការពារ៖** អ្នកវិទ្យាសាស្ត្រត្រូវតែការពារសេចក្តីសន្និដ្ឋាននៃការស្រាវជ្រាវរបស់ពួកគេ។

លោក ដាវីនពូកែធ្វើនៅលេខ១ (គំនិត) និងលេខ៤ (ការពារ) ប៉ុន្តែគាត់ស្ទើរតែមិនដែលធ្វើលេខ២ (សម្មតិកម្ម) និងលេខ៣ (ការពិសោធន៍)សោះ។ ក៏ប៉ុន្តែសម្មតិកម្ម និងការពិសោធន៍ គឺជាបេះដូងនៃវិធីសាស្ត្រវិទ្យាសាស្ត្រ។ ផ្ទុយពីនោះ វិធីសាស្ត្រផ្ទាល់ខ្លួនរបស់លោក ដាវីន គឺចំណាយពេលច្រើន បង្កើតគំនិតថ្មីដោយភាពច្នៃប្រឌិត អំពីលទ្ធភាពផ្សេងៗ (គឺលេខ១៖ គំនិត)។ ប៉ុន្តែគាត់ស្ទើរតែមិនដែលបង្ខំខ្លួនដើម្បីសង្ខេបគំនិតរបស់គាត់ ទៅជាសម្មតិកម្មដែលអាចពិសោធដោយគាត់ និងអ្នកវិទ្យាសាស្ត្រដទៃទៀត ដើម្បីដឹងថា តើវាត្រូវ ឬខុស

នោះទេ។ ផ្ទុយទៅវិញគាត់ប្រើការនិទានរឿងច្នៃប្រឌិត ដើម្បីធ្វើជាភស្តុតាង«បញ្ជាក់» ពីគំនិតរបស់គាត់។ បន្ទាប់មកជំនួសឲ្យការបង្កើតការពិសោធន៍ ដើម្បីសាកល្បងសម្មតិកម្ម គាត់បានយកឧទាហរណ៍ដែលគាត់បានឃើញពីធម្មជាតិដែលហាក់ដូចជា«បញ្ជាក់»ពីគំនិតរបស់គាត់។ គាត់មិនបានធ្វើតាមដំណើរការវិទ្យាសាស្ត្រផ្លូវការទេ។



*មន្ទីរពិសោធន៍* *James Gathany*




# ៣

# លោក ដាវីនខុសអំពីភូគព្ភសាស្ត្រ

សៀវភៅពីរក្បាលគត់ដែលលោក ដាវីនបានយកជាមួយគាត់ក្នុងការធ្វើដំណើរដ៏ល្បីល្បាញរបស់គាត់នៅកប៉ាល់ អេច អ៊ឹម អេស ប៊ីហ្គល (H.M.S. *Beagle*) គឺព្រះគម្ពីរបរិសុទ្ធ និងសៀវភៅភាគ១ របស់លោក ឆាលស៍ ឡៃអែល ដែលមានចំណងជើងថា «គោលការណ៍ភូគព្ភសាស្ត្រ» (នៅក្នុងរូបខាងលើ)។ យើងនឹងឃើញថា សៀវភៅទាំងពីរនេះប្រឆាំងគ្នា។ ពីរបីខែ បន្ទាប់ពីគាត់


*លោក ឆាលស៍ ឡៃអែល*

បានចាកចេញពីកំពង់ផែនៅប្រទេសអង់គ្លេស លោក

ដាវីនបានសំរេចចិត្តថា ព្រះគម្ពីរមិនពិតទេ គឺគ្រាន់តែជារឿងរ៉ាវជាច្រើនដែលបង្កើតឡើងដោយមនុស្សល្ងង់ខ្លៅ។ ផ្ទុយទៅវិញ គាត់ចាប់ផ្តើមជឿលើភូគព្ភសាស្ត្ររបស់លោក ឆាលស៍ ឡៃអែល ដែលបង្រៀនថា គ្រប់របស់នៅផែនដីនេះបានកើតឡើងដោយដំណើរការយឺតៗបន្តិចម្តងៗ មិនមែនភ្លាមៗទេ។

## ភូគព្ភសាស្ត្រនៃដំណើរការផ្លាស់ប្តូរបន្តិចម្តងៗ

លោក ឆាលស៍ ឡៃអែល បានបង្រៀននៅក្នុងសៀវភៅរបស់គាត់ថា ផែនដីមានអាយុកាលរាប់ពាន់លានឆ្នាំ ហើយស្រទាប់ភូគព្ភសាស្ត្រនៅក្នុងផែនដី បានបង្កើតឡើងពីស្រទាប់ក្រោមដល់លើយ៉ាងយឺតៗ និងបន្តិចម្តងៗ ក្នុងរយៈពេលរាប់ពាន់លានឆ្នាំ។ (យើងអាចដឹងថា នេះមិនមែនជាការពិតទេ ព្រោះមិនមានសំណឹកតាមបន្ទាត់រវាងស្រទាប់នីមួយៗទេ។) លោក ឡៃអែលបាននិយាយថា ស្រទាប់ទាំងនេះ បានបង្ហាញហ្វូស៊ីលនៃភាវៈរស់ ដែលចាប់ផ្តើមពីចំណាស់ជាងគេបំផុតនៅស្រទាប់ខាងក្រោម។ គាត់បានបង្រៀនថា លក្ខណៈភូគព្ភសាស្ត្រសំខាន់ៗនៃផែនដី អាចត្រូវបានពន្យល់ដោយដំណើរការបន្តិចម្តងៗ មិនមែនដោយមហន្តរាយណាមួយដូចជាទឹកជំនន់ និង

អាចដ៏ផ្កាយ (អាកាសបាតុភូត) ដែលធ្លាក់ដល់ផែនដីនោះទេ។ ភូគព្ភសាស្ត្រដែលមានការផ្លាសប្តូរបន្តិចម្តងៗនេះ សមស្របនឹងការវិវត្តន៍បន្តិចម្តងៗរបស់លោក ដាវីន។



*លោក ដាវីនបានជិះកប៉ាល់ អេច អ៊ឹម អេស ប៊ីហ្គល (H.M.S. Beagle)*

## តើជ្រលងទន្លេសាន់តាគ្រូស (Santa Cruz) ត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច?

ក្នុងអំឡុងពេលធ្វើដំណើររបស់លោក ដាវីននៅនាវា ប៊ីហ្គល គាត់បានចូលរួមបេសកកម្មមួយ ដើម្បីសិក្សាពី ជ្រលងទន្លេសាន់តាគ្រូស នៅតំបន់ដែលឥឡូវនេះគេ ហៅថា ប្រទេសអាហ្សង់ទីន នៅអាមេរិកខាងត្បូង។



ខាងលើគឺជាគំនូរ នៃជ្រលងទន្លេសាន់តាគ្រូស នៅសម័យនោះ។ សូមកត់សម្គាល់ថា ជ្រលងនេះជ្រៅ និងធំទូលាយ ដែលមានច្រាំងខ្ពស់ទាំងសងខាង និងទន្លេតូចមួយនៅខាងក្រោមជ្រលងដ៏ជ្រៅនោះ។ លោក ដាវីនបានធ្វើការប៉ាន់ស្មានដ៏ល្បីមួយ អំពីជ្រលងនេះ។ គាត់បាននិយាយថា «ទន្លេនេះ វាមានថាមពលតិចតួចក្នុងការហូរនាំដីខ្សាច់។ ប៉ុន្តែនៅក្នុងរយៈពេលច្រើនសម័យ អាចមានលទ្ធផលដែលពិបាកស្មានបាន តាមរយៈការសំណឹកបន្តិចម្តងៗ»។ គំនិតរបស់គាត់គឺថា ជ្រលងដ៏ធំដែលមានទំហំរាប់គីឡូម៉ែត្រ ត្រូវបានឆ្លាក់ចេញដោយទន្លេតូចមួយពីគ្រាប់ខ្សាច់មួយទៅគ្រាប់ខ្សាច់មួយ អស់រយៈពេលរាប់លានឆ្នាំមកហើយ។



*Google Earth*

សព្វថ្ងៃនេះយើងអាច «ហោះហើរ» លើជ្រលងទន្លេសាន់តាគ្រូស ដោយប្រើហ្គូហ្គលអឺត (Google Earth)។ ខាងលើគឺជារូបភាព ហ្គូហ្គលអឺត នៃផ្នែកខាងលើនៃជ្រលងទន្លេសាន់តាគ្រូស។ អ្នកអាចមើលថា ជ្រលងមានទទឹងប៉ុណ្ណា (ប្រហែល២០គីឡូម៉ែត្រ) ហើយ ទន្លេតូចប៉ុណ្ណា បើប្រៀបធៀបនឹងជ្រលងនោះ។ អ្នកក៏អាចមើលឃើញថា ប្រភពនៃទន្លេសាន់តាគ្រូស គឺបឹងធំមួយឈ្មោះបឹងអាហ្សង់ទីណូ ដែលស្ថិតនៅបាតភ្នំអែនដេស នៅចំងាយឆ្ងាយ។ អ្នកអាចឃើញភ្នំសពីចម្ងាយ ដែលគ្របដណ្តប់ដោយព្រិល។ ប្រសិនបើយើង «ហោះហើរ» ទៅទៀតជិតភ្នំនោះ យើងនឹងឃើញភ្នំកាន់តែច្បាស់៖



*បឹងអាហ្សង់ទីណូ។ ភ្នំនេះខ្លះមានកំពស់ជាង ២៥០០ ម៉ែត្រ។* *Jeremy Woodhouse*

យើងអាចមើលឃើញថា បឹងអាហ្សង់ទីណូ ទទួលទឹកពីទឹកកករលាយពីផ្ទាំងទឹកកកដែលចុះពីភ្នំអែនដេស (Andes) ដែលគ្របដណ្ដប់ដោយព្រិលទឹកកកជានិច្ច។ កំឡុងយុគសម័យទឹកកក អ្វីៗទាំងអស់ដែលអ្នកឃើញនៅក្នុងរូបភាពនេះ លើកលែងតែកំពូលភ្នំខ្ពស់ជាងគេ ត្រូវបានគ្របដណ្ដប់ដោយទឹកកកដែលមានកម្រាស់២០០០ម៉ែត្រ!

សព្វថ្ងៃនេះភូគព្ភវិទូលែងជឿអ្វីដែលលោក ដាវីនបានជឿ គឺជ្រលងទន្លេសាន់តាគ្រូសត្រូវបានបង្កើតឡើងយឺតៗរាប់លានឆ្នាំមកហើយ។ ផ្ទុយទៅវិញ ពួកគេបានរកឃើញភស្តុតាងដែលបញ្ជាក់ថា ជ្រលងដ៏ធំនេះ ត្រូវបាន

បង្កើតឡើងក្នុងរយៈពេលដ៏ខ្លី។ តើកើតឡើងយ៉ាងដូចម្ដេច?

នៅចុងបញ្ចប់នៃយុគសម័យទឹកកក ទឹកកកដែលគ្របដណ្ដប់លើភ្នំ បានចាប់ផ្ដើមរលាយ។ ទឹកកកដែលមិនទាន់រលាយបានធ្វើជាទំនប់ទឹកកកមួយដ៏ធំនៅលើភ្នំ។ ទឹកដែលរលាយ បានកើនឡើងខ្ពស់ទៅៗ នៅក្រោយទំនប់ទឹកកកនោះ ហើយបង្កើតបានជាបឹងធំនិងជ្រៅ។ ក្រោយមកទំនប់ទឹកកកទាំងនេះបានបាក់ ហើយទឹកជំនន់ដ៏ធំបានហូរឆ្ពោះទៅមហាសមុទ្រអាត្លង់ទិក ចម្ងាយ ២៥០គីឡូម៉ែត្រ។ ទឹកជំនន់ដ៏កាចសាហាវនេះ បានបង្កើតជ្រលងទន្លេសាន់តាគ្រូសក្នុងរយៈពេលដ៏ខ្លី មិនមែនប្រើពេលរាប់លានឆ្នាំនោះឡើយ។

ប្រភេទភូគព្ភសាស្ត្រដែលលោក ឆាលស៍ ឡៃអែល បានបង្រៀន ហើយដែលលោក ឆាលស៍ ដាវីនបានទទួលយក ឥឡូវត្រូវបានគេទាត់ចោលហើយ។ លោក ឡៃអែល បានអះអាងថា យើងមិនត្រូវការព្រឹត្តិការណ៍មហន្តរាយដើម្បីពន្យល់ពីភូគព្ភសាស្ត្រផែនដីទេ។ ប៉ុន្តែភូគព្ភវិទូនាពេលថ្មីៗនេះបានបង្ហាញពី ឧទាហរណ៍ជាច្រើន ដែលបញ្ជាក់ពី គ្រោះមហន្តរាយដ៏ធំ ដូចជា អាចដ៏ផ្កាយ

(អាកាសបាតុភូត) ដែលបានបុកផែនដី និងទឹកជំនន់ដ៏ធំ ដែលបានកើតឡើងជាច្រើនកន្លែងនៅផែនដីនេះ។ លោកដាវីនបានជ្រើសរើសសៀវភៅខុសដើម្បីធ្វើជាមូលដ្ឋាននៃទស្សនៈរបស់គាត់។ គាត់គួរតែជ្រើសរើសយកព្រះគម្ពីរវិញ។



# ៤

# លោក ដាវីនខុសអំពីហ្វូស៊ីល

ហ្វូស៊ីល គឺជាសំណល់នៃរុក្ខជាតិ ឬសត្វដែលត្រូវបានកប់ក្នុងដី ហើយបានក្លាយជាថ្ម។ ខ្ញុំបានជ្រើសរើសរូបភាពហ្វូស៊ីល ស៊ីឡឺខេនត៍ (coelacanth – រូបខាងលើ) ដើម្បីរំឭកយើងថា លោក ដាវីនក៏ខុសអំពីហ្វូស៊ីលដែរ។ ត្រីស៊ីឡឺខេនត៍ គឺជាហ្វូស៊ីលដ៏ល្បីល្បាញដែលលេចឡើងជាញឹកញាប់នៅក្នុងស្រទាប់ផ្សេងៗគ្នានៃស្រទាប់ភូគព្ភសាស្ត្រ។ ត្រីស៊ីឡឺខេនត៍ បានរស់នៅរយៈពេលរាប់រយលានឆ្នាំ ប៉ុន្តែក្រោយមកបានផុតពូជ តាំងពី៦៥លានឆ្នាំមុន (យោងទៅតាមការបកស្រាយមួយនៃកំណត់ត្រាហ្វូស៊ីល)។ ជាងនេះទៅទៀត ដោយសារហ្វូស៊ីលបាន

បង្ហាញថា ត្រីស៊ីឡឺខេនត៍មានព្រុយធំជាងធម្មតា អ្នកវិទ្យាសាស្ត្រជឿថា ត្រីនេះគឺជាត្រីអន្តរកាលមួយ ដែលនៅចន្លោះពាក់កណ្ដាលរវាងត្រី និងសត្វជើងបួន។ វិទ្យាសាស្ត្រវិវត្តន៍ បានប៉ាន់ស្មានថា ត្រីទាំងនេះរស់នៅក្នុងទឹករាក់ ហើយប្រើព្រុយធំៗ ដូចជាជើងដើម្បីវារតាមបាត ហើយថែមទាំង«ដើរ»ចេញពីទឹកមកលើដីគោកទៀតផង។



*ត្រីស៊ីឡឺខេនត៍សព្វថ្ងៃនេះ* jonnysek 123rf.com/profile_jonnysek

ក៏ប៉ុន្តែនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៣៨ អ្នកនេសាទនៅអាហ្វ្រិកខាងត្បូង បានចាប់បានត្រីស៊ីឡឺខេនត៍ដែលនៅរស់! ហើយចាប់តាំងពីពេលនោះមក មានមនុស្សជាច្រើនផ្សេងទៀត បានឃើញ និងចាប់បានត្រី ស៊ីឡឺខេនត៍ដែរ។ ឥឡូវយើងដឹងហើយថា ត្រីស៊ីឡឺខេនត៍ មិនមែនជាទម្រង់ផ្លាស់ប្ដូរអន្តរកាល រវាងត្រីនិងសត្វជើងបួនទេ ប៉ុន្តែវាគ្រាន់តែជាត្រីធម្មតាប៉ុណ្ណោះ។ មិនត្រឹមតែប៉ុណ្ណោះ វាមិន

រស់នៅក្នុងទឹករាក់ទេ ប៉ុន្តែវាហែលជាធម្មតានៅក្នុងទឹកជ្រៅ។

## តើទម្រង់អន្តរកាលបានបាត់ទៅណា?

មុននឹងខ្ញុំប្រាប់អ្នកពីរបៀបដែលលោក ដាវីនគិតខុសអំពីហ្វូស៊ីល ខ្ញុំចង់ប្រាប់អ្នកអំពីរឿងមួយដែលគាត់និយាយត្រូវ។ លោក ដាវីន បានទទួលស្គាល់យ៉ាងត្រឹមត្រូវថា កំណត់ត្រាហ្វូស៊ីលនៅសម័យរបស់គាត់ បានបង្ហាញថា ទ្រឹស្តីនៃការវិវត្តន៍របស់គាត់គឺមិនពិតទេ។ កំណត់ត្រាហ្វូស៊ីលបានបង្ហាញពីសារពាង្គកាយជាច្រើនប្រភេទលេចឡើងនៅក្នុងស្រទាប់ខេមប្រៀន (Cambrian) ដោយមានគ្រប់លក្ខណៈហើយ។ (ស្រទាប់ខេមប្រៀន គឺជាស្រទាប់ស្ទើរតែទាបបំផុតនៅក្នុងកំណត់ត្រាហ្វូស៊ីល។) ប៉ុន្តែស្រទាប់ក្រោមខេមប្រៀន គ្មានហ្វូស៊ីលនៃសត្វនោះសោះ។ លោក ដាវីនបាននិយាយថា «ចំពោះសំណួរថា ហេតុអ្វីបានជាយើងមិនរកឃើញ ហ្វូស៊ីលជាច្រើន នៅស្រទាប់មុនស្រទាប់ខេមប្រៀន ខ្ញុំមិនអាចផ្តល់ចម្លើយដែលពេញចិត្តបានទេ»។

លោក ដាវីនយល់ថា ការផ្ទុះនៃទម្រង់ជីវិតជាច្រើននៃហ្វូស៊ីលក្នុងស្រទាប់ខេមប្រៀន ដែលមានលក្ខណៈ

ពេញលេញនិងស្មុគស្មាញហើយ មិនសមនឹងទ្រឹស្តីរបស់គាត់ នៃការផ្លាស់ប្តូរបន្តិចម្តងៗនោះទេ។

គាត់ក៏យល់ទៀតថា កំណត់ត្រាហ្វូស៊ីលនៅសម័យរបស់គាត់ មិនបានបង្ហាញពីសារពាង្គកាយផ្លាស់ប្តូរបន្តិចម្តងៗ តាមពេលវេលានោះទេ ប៉ុន្តែហ្វូស៊ីលសត្វនោះមិនបានផ្លាស់ប្តូរសោះ។ គាត់បាននិយាយថា «អ្នកបុរាណវិទូដែលល្បីល្បាញជាងគេគឺ លោក ខូវៀរ (Cuvier) លោក អាហ្គាសហ្ស៊ីស (Agassiz) លោក បារ៉ាន់ដេ (Barrande) លោក ភីកថេត (Pictet) លោក ហ្វាលខនណឺរ (Falconer) លោក អ៊ី ហ្វបស៍ (E. Forbes) ។ល។ ជាមួយនឹង ភូគព្ភវិទូសំខាន់ជាងគេ គឺ លោក ឡៃអិល (Lyell) លោក ម៉ឺជីសិន (Murchison) លោក សេដវិច (Sedgewick) ។ល។ **បាននាំគ្នាបញ្ជាក់ថា សត្វមិនអាចផ្លាស់ប្តូរទេ**»។ និយាយម្យ៉ាងទៀត បុរាណវិទូ និងភូគព្ភវិទូធំជាងគេនៅសម័យលោក ដាវីន បានសិក្សាពីហ្វូស៊ីលទាំងអស់ ហើយឃើញថា ហ្វូស៊ីលទាំងនោះ មិនបានបង្ហាញភស្តុតាងណាមួយ នៃការផ្លាស់ប្តូរបន្តិចម្តងៗ តាមទ្រឹស្តីរបស់លោក ដាវីនឡើយ។ ផ្ទុយទៅវិញភស្តុតាងហ្វូស៊ីលបានបង្ហាញថា ទម្រង់

មូលដ្ឋាននៃប្រភេទសត្វនីមួយៗមិនបានផ្លាស់ប្តូរក្នុងកំឡុងពេលរបស់វា ក្នុងកំណត់ត្រាហ្វូស៊ីល (ទោះបីជាពេលវេលានោះមានរាប់លានឆ្នាំក៏ដោយ យោងទៅតាមតារាងកាលវេលារបស់ទ្រឹស្តីវិវត្តន៍)។

កំណត់ត្រាហ្វូស៊ីលបានបង្កើតបញ្ហាដ៏ធំសម្រាប់លោក ដារវីន។ ទ្រឹស្តីរបស់គាត់បាននិយាយថា សត្វត្រូវតែផ្លាស់ប្តូរយ៉ាងយឺតៗបំផុត តាមរយៈពេលវេលាដ៏យូរបំផុតរបស់វា។ ផ្ទុយទៅវិញ កំណត់ត្រាហ្វូស៊ីលបានបង្ហាញថា សត្វទាំងអស់លេចឡើងក្នុងកំណត់ត្រាហ្វូស៊ីលដោយមានពេញលក្ខណៈស្រាប់  ហើយមិនផ្លាស់ប្តូររូបរាងរបស់វាទេ។ ដូច្នេះគ្មានទម្រង់អន្តរកាលទេ។ លោក ដារវីនឆ្ងល់មែនទែនអំពីបញ្ហានេះ ហើយបានសសេរថា «ហេតុអ្វីបានជារាល់ស្រទាប់ភូគព្ភសាស្រ្តមិនពោរពេញទៅដោយទម្រង់អន្តរកាលនេះ? តែភូគព្ភសាស្រ្តប្រាកដជាមិនបង្ហាញសង្វាក់សរីរាង្គដែលផ្លាស់ប្តូរបន្តិចម្តងៗនោះទេ។ ហើយការពិតនេះ គឺជាការប្រឆាំងច្បាស់ជាងគេ និងធ្ងន់ធ្ងរជាងគេ ទាស់នឹងទ្រឹស្តីនេះ» (*The Origin of Species*, 1859)។ លោក ដារវីននិយាយត្រូវហើយ។

កំណត់ត្រាហ្វូស៊ីល គួរមានទម្រង់អន្តរកាលរាប់លានមែន។

ដូច្នេះ តើការខ្វះអន្តរកាលនៅក្នុងកំណត់ត្រាហ្វូស៊ីលបាននាំឲ្យលោក ដារីន សង្ស័យលើទ្រឹស្តីរបស់គាត់ដែរឬទេ? អត់ទេ ផ្ទុយទៅវិញគាត់បានបន្ទោសលើកំណត់ត្រាហ្វូស៊ីលវិញ។ គាត់និយាយថា «បញ្ហាគឺស្ថិតនៅក្នុងភាពខ្វះនៃកំណត់ត្រាភូគព្ភសាស្ត្រ»។

និយាយម្យ៉ាងទៀតគាត់សង្ឃឹមថា បើយើងរកឃើញហ្វូស៊ីលកាន់តែច្រើន យើងនឹងឃើញហ្វូស៊ីលអន្តរកាលរាប់លានដែរ។ ក៏ប៉ុន្តែ ១៦០ឆ្នាំក្រោយមក ភូគព្ភសាស្ត្រនៅតែ «មិនបង្ហាញពីសង្វាក់សរីរាង្គយ៉ាងល្អិតល្អន់បែបនេះទេ...»។ តាំងពីសម័យលោក ដារីនមក ហ្វូស៊ីលចំនួនមួយពាន់លានទៀតត្រូវបានរកឃើញ ហើយក្នុង ចំណោមហ្វូស៊ីលនោះ ចំនួន ២៥០លានត្រូវបានចុះបញ្ជីជាផ្លូវការដោយអ្នកវិទ្យាសាស្ត្រ។ ឥឡូវនេះ យើងមានកំណត់ត្រាហ្វូស៊ីលស្ទើរតែគ្រប់ហើយ។ ដូច្នេះតើយើងបានរៀនអ្វីទៅពីហ្វូស៊ីលមួយពាន់លាននោះ? យើងបានរៀនថា កំណត់ត្រាហ្វូស៊ីល**នៅតែ**មិនពោរពេញតាមតំណរអន្តរកាល ដូចអ្វីដែលលោក ដារីនបានសង្ឃឹមនោះទេ។

ឧទាហរណ៍អំពីហ្វូស៊ីលអន្តរកាល៖ ប្រសិនបើស្តេចខ្មែរបុរាណមួយអង្គ ដើម្បីទទួលបានអំណាចខាងវិញ្ញាណ បានធ្វើខ្សែត្បូងទទឹម និងពេជ្រដ៏វែងបំផុតមួយខ្សែ ពីវាំងរបស់ទ្រង់នៅសៀមរាប រហូតដល់វាំងនៅភ្នំពេញ ចម្ងាយ ៣០០គីឡូម៉ែត្រ។ រាល់ត្បូងទទឹម១០០គ្រាប់ម្តង ទ្រង់បានដាក់ពេជ្រមួយគ្រាប់ ហើយធ្វើដូច្នេះរហូតដល់ភ្នំពេញ។ ទ្រង់បានកប់ខ្សែត្បូងនេះនៅក្នុងដី ហើយបានបំភ្លេចចោល។ ខ្សែដែលភ្ជាប់ត្បូងបានពុកផុយទៅ ហើយត្បូងត្រូវបានបំបែកពីគ្នាទៅក្នុងដី។ មួយពាន់ឆ្នាំក្រោយមក កសិករម្នាក់បានរកឃើញត្បូងខ្លះនៅក្នុងចំការរបស់គាត់។ មិនយូរប៉ុន្មាន មនុស្សម្នាពីសៀមរាបទៅភ្នំពេញកំពុងជីករកត្បូងទាំងនោះដែរ។ នេះជាសំណួររបស់ខ្ញុំ៖ តើមនុស្សជីកនោះនឹងរកឃើញពេជ្រច្រើនជាងត្បូងទទឹម ឬ រកឃើញត្បូងទទឹមច្រើនជាងពេជ្រ? បាទ គួររកឃើញត្បូងទទឹមច្រើនជាង១០០ដង! ចុះបើគេរកឃើញតែគ្រាប់ពេជ្រវិញ? នេះជារឿងមិនអាចទៅរួចទេ។

នេះហើយជាបញ្ហានៃកំណត់ត្រាហ្វូស៊ីលសម្រាប់អ្នកវិវត្តន៍និយម។ គួរមានហ្វូស៊ីលអន្តរកាលច្រើនជាងហ្វូស៊ីលដើមនិងចុង។ ច្រើនជាងឆ្ងាយ! ប៉ុន្តែហ្វូស៊ីល

អន្តរកាលស្ទើរតែគ្មានទេ។ ជាឧទាហរណ៍ ប្រសិនបើសត្វល្មូនបានផ្លាស់ប្តូរបន្តិចម្តងៗទៅជាសត្វស្លាប តាមជំហានតូចៗរាប់លានជំហាន តាមរយៈពេលវេលារាប់លានឆ្នាំ (តាមការអះអាងនៃទ្រឹស្តីវិវត្តន៍) នោះកំណត់ត្រាហ្វូស៊ីលគួរតែមានហ្វូស៊ីលអន្តរកាល **ច្រើនជាង**ហ្វូស៊ីលនៃសត្វល្មូនដើម និងសត្វស្លាបចុងទៅទៀត។ ប៉ុន្តែអ្វីទាំងអស់ដែលយើងរកឃើញ នៅកំណត់ត្រាហ្វូស៊ីល គឺហ្វូស៊ីលសត្វល្មូនរាប់លាន និងហ្វូស៊ីលបក្សីរាប់លាន ប៉ុន្តែគ្មានហ្វូស៊ីលអន្តរកាលនោះទេ។

## «ការលាក់គំនួចនៃបុរាណវិទ្យា»

អ្នកបុរាណវិទូបច្ចុប្បន្ននេះក៏ទទួលស្គាល់បញ្ហានេះដែរ។ លោក ស្ទេហ្វិន ចេ ហ្គោល (Stephen Jay Gould) ដែលជាអ្នកបុរាណវិទូល្បីឈ្មោះបំផុតមួយនៅចុងសតវត្សរ៍ទី២០ បាននិយាយថា «ភាពកម្រមានបំផុតនៃទម្រង់អន្តរកាលនៅក្នុងកំណត់ត្រាហ្វូស៊ីល នៅតែជា "ការលាក់គំនួច" នៃបុរាណវិទ្យា។ រូបដើមឈើជីវិត [ដើមឈើវិវត្តន៍] ដែលមាននៅសៀវភៅរៀនរបស់យើង មានរូបភាព[សត្វ] នៅគល់មែក និងចុងមែកប៉ុណ្ណោះ។ អ្វីដែលនៅកណ្តាល គ្រាន់តែជាការស្មានតែប៉ុណ្ណោះ...

មិនមែនជាភស្តុតាងពិតនៃហ្វូស៊ីលទេ»!! អ្នកបុរាណវិទូដ៏ល្បីល្បាញម្នាក់ទៀតឈ្មោះលោក នែលស៍ អេលឌ្រើដ (Niles Eldredge) បានសារភាពថា «...មួយរយម្ភៃឆ្នាំនៃការស្រាវជ្រាវបុរាណវិទ្យា បានបង្ហាញយ៉ាងច្បាស់ថា កំណត់ត្រាហ្វូស៊ីល នឹងមិនបញ្ជាក់ពីផ្នែកនេះនៃការទស្សនទាយរបស់លោក ដាវីនឡើយ»!! (N. Eldredge, and I. Tattersall, *The Myths of Human Evolution*, Columbia University Press, 1982, pp. 45–46)។ អ្នកបុរាណវិទូទាំងនេះ គឺជាអ្នកវិវត្តន៍និយមខ្លាំង តែពួកគេបានសារភាពថា កំណត់ត្រាហ្វូស៊ីលមិនបានគាំទ្រទ្រឹស្តីវិវត្តន៍របស់លោក ដាវិនទេ។

លោក ដាវីនក៏បានចាត់ទុកការខ្វះទម្រង់អន្តរកាលថា ជាភស្តុតាងខ្លាំងជាងគេ ប្រឆាំងនឹងការវិវត្តន៍។ មួយរយហុកសិបឆ្នាំក្រោយមក ការខ្វះទម្រង់អន្តរកាលនេះនៅតែជាភស្តុតាងដ៏ខ្លាំងជាងគេប្រឆាំងនឹងការវិវត្តន៍។ លោក ដាវីនសង្ឃឹមថា មនុស្សនឹងរកឃើញហ្វូស៊ីលដែលគាំទ្រទ្រឹស្តីដែលថា ទម្រង់នៃជីវិតជាច្រើនបានមកពីបុព្វបុរសតែមួយ ដូចនៅក្នុង «ដើមឈើ» ក្នុងតារាងទី១នេះ ៖




***តារាងទី១៖*** *លោក ដាវីនសង្ឃឹមថា កំណត់ត្រាហ្វូស៊ីលនឹងបង្ហាញថា មានសត្វដើមមួយ ដែលវិវត្តន៍បែកទៅជាសត្វដទៃបន្តិចម្តងៗ ហើយនិងវិវត្តន៍ទៀត ទៅជាសត្វដទៃទៀត។*

ផ្ទុយទៅវិញ កំណត់ត្រាហ្វូស៊ីលបានបង្ហាញសត្វទាំងអស់លេចឡើងក្នុងកំណត់ត្រាដោយមានទម្រង់ពេញលេញរួចហើយ ហើយមិនបានផ្លាស់ប្តូរអ្វីទេ៖




***តារាងទី២៖*** *សត្វលេចឡើងនៅក្នុងកំណត់ត្រាហ្វូស៊ីលដោយមានរូបរាងដ៏ពេញលេញ ហើយវាមិនផ្លាស់ប្តូរសោះក្នុងរយៈពេលរាប់លានឆ្នាំ (យោងទៅតាមពេលវេលាវិវត្ត)។*

នៅក្នុងតារាងទី២នេះ បន្ទាត់ពណ៌ក្រហមនីមួយៗ តំណាងឲ្យ ប្រភេទរាងកាយរបស់សត្វជាក់លាក់នៅក្នុង កំណត់ត្រាហ្វូស៊ីល។ ផ្នែកខាងក្រោមនៃតារាងនោះ គឺ សម័យកាលដើមដំបូង ហើយខាងលើគឺសម័យកាល ក្រោយមក។ សូមកត់សម្គាល់ថា សត្វលេចឡើងនៅក្នុង កំណត់ត្រាហ្វូស៊ីល មានគ្រប់លក្ខណៈស្រាប់ ហើយបាត់ ទៅវិញពីកំណត់ត្រាហ្វូស៊ីល ដោយមិនផ្លាស់ប្តូរអ្វីសោះ (មិនមានការបែកមែកទេ)។ មិនត្រឹមតែប៉ុណ្ណោះ មិនមាន សត្វដើមដំបូងរួមទេ ដែលបានផ្លាស់ប្តូរបន្តិចម្តងៗ ទៅជា សត្វឯទៀត។ តារាងទី១ខាងលើ គឺជាអ្វីដែលលោក ដាវីន សង្ឃឹមថា កំណត់ត្រាហ្វូស៊ីលនឹងបង្ហាញ គឺ សត្វដើម មួយ ដែលវិវត្តន៍បែកទៅជាសត្វដទៃបន្តិចម្តងៗ ហើយ និងវិវត្តន៍ទៀត ទៅជាសត្វដទៃទៀត។ ប៉ុន្តែឥឡូវនេះ ១៦០ឆ្នាំក្រោយលោក ដាវីន យើងមានហ្វូស៊ីល១ពាន់ លានហើយ តែកំណត់ត្រាហ្វូស៊ីលមិនបានបញ្ជាក់ពីទ្រឹស្តី វិវត្តន៍របស់លោកទេ។ លោក ដាវីនខុសអំពីកំណត់ត្រា ហ្វូស៊ីល។




# ៥

# លោក ដាវីនខុសអំពីដើមឈើវិវត្តន៍

ខាងលើគឺជាទំព័រមួយនៃសៀវភៅកំណត់ហេតុរបស់លោក ដាវីន ដែលគាត់សរសេរពាក្យ «ខ្ញុំគិត» ជាមួយនឹងគំនូរដើមឈើដែលបែកមែក។ គំនូរនេះ គឺជា «ដើមឈើជីវិត» (ឬដើមឈើនៃការវិវត្តន៍) របស់លោក ដាវីន។ អ្នកអាចឃើញលេខ ១ នៅគល់ដើមឈើនេះ ដែលជាកោសិកាជីវិតដំបូងបង្អស់ ដែលយូរទៅបែកជាសារពាង្គកាយផ្សេងៗ ដែលមកពីជីវិតដំបូងនោះ។ ពេលខ្ញុំជាអ្នកវិវត្តន៍និយម ខ្ញុំជឿថា ដើមឈើជីវិតបែបនេះ គឺជាភស្តុតាងដ៏ល្អបំផុតមួយសម្រាប់ការវិវត្តន៍។ ចូរយើងគិតអំពីការនេះ។

## ដើមឈើជីវិតពិត មិនមែនជាដើមឈើទេ

ខាងក្រោមនេះយើងឃើញម្តងទៀត នូវតារាងនៃកំណត់ត្រាហ្វូស៊ីល។ ផ្នែកខាងក្រោមនៃតារាងទាំងពីរនេះ តំណាងឲ្យយុគសម័យដើម ហើយផ្នែកខាងលើនៃតារាង តំណាងឲ្យយុគសម័យថ្មីជាង។

### ដាវីនសង្ឃឹមថា ហ្វូស៊ីលដែលគេរកឃើញនឹងបញ្ជាក់ពីការនេះ ៖




### តែភស្តុតាងហ្វូស៊ីលបញ្ជាក់ពីការនេះវិញ៖



កំណត់ត្រាហ្វូស៊ីលពិតប្រាកដនៅខាងក្រោម គ្មានរូបរាងដើមឈើទេ។ វាមើលទៅដូចជារបងវិញ។ ប្រភេទសត្វនីមួយៗលេចឡើងភ្លាមៗ ក្នុងកំណត់ត្រាហ្វូស៊ីល ហើយមិនផ្លាស់ប្តូរ រហូតដល់វាបាត់ចេញពីកំណត់ត្រាហ្វូស៊ីលវិញ។ ប៉ុន្តែអ្នកវិវត្តន៍និយមត្រូវការរូបរាងដើមឈើវិញ ដូចតារាងខាងលើ មិនមែនរូបរាងរបងទេ ព្រោះពួកគេជឿថា ជីវិតទាំងអស់ចេញមកពីកោសិការដើមមួយ។ ដូច្នេះប្រសិនបើអ្នកវិវត្តន៍និយមឃើញថា កំណត់ត្រាហ្វូស៊ីលនឹងផ្តល់នូវ «របងនៃជីវិត» ជំនួសឲ្យ«ដើមឈើនៃជីវិត» ពួកគេត្រូវរកវិធីមួយទៀត ដើម្បីបង្ហាញភស្តុតាងនៃកោសិការដើមមួយដែលបំបែកជាសត្វទាំងអស់។ តើគេរកភស្តុតាងពីណា? គេប្រើវិទ្យាសាស្រ្តនៃ ហ្វៃឡូចិននី (phylogeny)។

តើ ហ្វៃឡូចិននី មានន័យដូចម្តេច? ហ្វៃឡូចិននី មានន័យថា អ្វីៗទាំងអស់នៅក្នុងពិភពលោក ទាំងមានជីវិត និងគ្មានជីវិត អាចដាក់ជាក្រុមផ្សេងៗតាមលក្ខណៈដូចគ្នា និងលក្ខណៈខុសគ្នា។ ឧទាហរណ៍ នៅផ្ទះបាយរបស់យើង យើងទុកចាន និងចានគោម ដាច់ដោយឡែកពីគ្នាជាជង់ពីរនៅលើធ្នើរ ពីព្រោះចាន និងចានគោមមាន

លក្ខណៈខុសគ្នា។ ប៉ុន្តែយើងក៏ដឹងដែរថា ចាន និង ចានគោមក៏មានលក្ខណៈដូចគ្នាដែរ (វាទាំងពីរប្រើសម្រាប់ ដាក់បាយនិងម្ហូប)។ ដូច្នេះយើងទុកចាន និងចានគោម ក្បែរគ្នា នៅលើធ្នើតែមួយ។ ប៉ុន្តែយើងអាចទុកពែង និង កែវ នៅកន្លែងផ្សេង។ ហើយយើងទុកញញួរ និងទួណឺវីស នៅកន្លែងផ្សេងទៀត។ យើងមិនទុកញញួររបស់យើង ជាមួយចាន និងស្លាបព្រាទេ!

ដូចគ្នាដែរ អ្នកវិទ្យាសាស្ត្រខាងហ្វេឡូចិននីអាចបែង ចែកដំណាំ និងសត្វជាក្រុមផ្សេងៗ តាមភាពដូចគ្នា និង ខុសគ្នា។ ប៉ុន្តែពួកគេក៏ឈានមួយជំហានទៀត គឺពួកគេ សង្កេតមើលប្រភេទសត្វសព្វថ្ងៃនេះ (គឺសត្វនៅចុងមែក នៃដើមឈើរបស់ លោក ដាវីន) ហើយប្រើភាពដូចគ្នា និង ភាពខុសគ្នានោះ ដើម្បី**ស្មាន**ថា សត្វណាវិវត្តន៍មកពីសត្វ ណា ហើយសត្វណាខ្លះមានជីដូនជីតារួមគ្នា។ បញ្ហាគឺ យើងមិនអាចដឹងពីអតីតកាល តាមរយៈការសិក្សានា ពេលបច្ចុប្បន្នបាននោះទេ។ បើយើងសិក្សានាពេល បច្ចុប្បន្ន នោះយើងអាចដឹងពីពេលបច្ចុប្បន្នតែប៉ុណ្ណោះ។ ដើម្បីប្រើពេលបច្ចុប្បន្ន ទៅសិក្សាពីអតីតកាល គឺវា គ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។

ខាងក្រោមនេះ ជាដើមឈើវិវត្តន៍ដែលគេគូរពីសតវត្សមុន។ គំនូរបែបនេះមិនផ្អែកលើភស្តុតាងហ្វូស៊ីលនោះទេ ប៉ុន្តែវាផ្អែកលើគំនិតរបស់មនុស្សដែលប៉ាន់ស្មានអំពីសត្វណាខ្លះគួរដាក់ជាក្រុមជាមួយគ្នា។ ទាក់ទងនឹងសត្វនាពេលបច្ចុប្បន្ន វាមិនពិបាកក្នុងការដាក់សត្វជាក្រុមជាមួយគ្នាឲ្យត្រឹមត្រូវ តាមលក្ខណៈដូចគ្នា និងខុសគ្នារបស់វានោះទេ។ ប៉ុន្តែវាពិបាកប្រើព័ត៌មានបច្ចុប្បន្ន ដើម្បីដឹងថា សត្វណាជាជីដូនជីតាដើម (ជាពិសេសនៅពេលគ្មានភស្តុតាងហ្វូស៊ីលនៃជីដូនជីតាទាំងនោះផង)។



*ដើមឈើវិវត្តន៍ពីសតវត្សមុន*

ខាងក្រោមនេះគឺជាដើមឈើវិវត្តន៍មួយប្រភេទទៀត (ហៅថា ក្លាដូក្រាម cladogram)។ ប៉ុន្តែសូមកត់សំគាល់ម្តងទៀតថា តារាងមានតែរូបភាពសត្វបច្ចុប្បន្នប៉ុណ្ណោះទេ។ តើរូបភាពនៃជីដូនជីតាដើម នៃសត្វបច្ចុប្បន្នទាំងនេះនៅឯណា? ពួកគេគ្មានរូបភាពនៃសត្វអន្តរកាល នៅលើដើមឈើវិវត្តន៍នេះទេ។ ហេតុអ្វីមិនមាន? ដោយសារតែគេមិនដឹងអ្វីអំពីពួកវាទេ ព្រោះកំណត់ត្រាហ្វូស៊ីលមិនមាន។ ដើមឈើវិវត្តន៍ខាងក្រោមនេះគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។




អស់រយៈពេល៧១០០ឆ្នាំកន្លងមក ការគូរ«ដើមឈើជីវិត»ថ្មី បានក្លាយជាការគិតមមៃរបស់អ្នក វិទ្យាសាស្ត្រ។

អ្នកវិទ្យាសាស្ត្ររាប់ពាន់នាក់ បានគូរដើមឈើជីវិត រាប់ពាន់យ៉ាង ប៉ុន្តែគ្មានដើមឈើណាមួយដែលមាន មូលដ្ឋានលើភស្តុតាងហ្វូស៊ីលនោះទេ។ គេផ្អែកលើការ ដែលគេសង្កេតមើលភាពដូចគ្នា និងភាពខុសគ្នារវាងភាវៈ រស់។ គំនូរខ្លះមានរាងមូល ដូចជាការមើលដើមឈើពី ខាងលើ ហើយខ្លះទៀតរាងខ្ពស់៖




ទីបំផុត នៅឆ្នាំ២០០៩ ទស្សនាវដ្ដីវិទ្យាសាស្ត្រដែល មានឈ្មោះ *New Scientist* បានបោះពុម្ពច្បាប់មួយ អំពីបញ្ហានេះ យ៉ាងស៊ីជម្រៅ។ នេះគឺជាគម្របនៃ ទស្សនាវដ្ដីនោះ៖




ចំណងជើងនិយាយថា «លោក ដារីនខុស» ហើយចំណងជើងក្រោមគឺ «ការកាប់ដើមឈើនៃជីវិត»។ អត្ថបទនោះនិយាយអំពីអសមត្ថភាពសម្រាប់សហគមន៍វិទ្យាសាស្ត្រ ក្នុងការបង្កើតដើមឈើនៃជីវិតត្រឹមត្រូវ។ ហើយពួកគេបានទទួលស្គាល់ថា ពួកគេមិនអាចដឹងថា សត្វណាមកពីសត្វណា ហើយសត្វណាជាសត្វដើមរួមនោះទេ។ ដូច្នេះ ការស្រាវជ្រាវថ្មីៗនេះបង្ហាញថា ដើមឈើនៃជីវិតរបស់វិវត្តន៍កំពុងដួលចុះហើយ។

អ្នកវិទ្យាសាស្ត្រម្នាក់ដែលត្រូវបានសម្ភាសនៅក្នុងអត្ថបទនោះ គឺជាអ្នកជំនាញខាង ហ្វៃឡូចិននី (phylogeny) ដ៏ល្បីល្បាញម្នាក់ឈ្មោះ ហ្វត ដូលីតថល (W. Ford Doolittle)។ គាត់បានសរសេរអត្ថបទ

មួយទៀតដែលមានចំណងជើងថា «ដកដើមឈើជីវិតចោល» (Uprooting the Tree of Life) បោះពុម្ពផ្សាយដោយ *Scientific American* នៅឆ្នាំ ២០០០។ គាត់បានផ្តល់គំនូរស្មុគស្មាញនៃដើមឈើជីវិត ដោយសារភាពថា វាជាការស្មុគស្មាញពេក មើលទៅដូចជា «មីស្លាកីទី»មួយចាន មិនមែនជាដើមឈើនោះទេ ៖




ដូច្នេះ គាត់បានហៅវាថា ជា«បណ្តាញជីវិត» មិនមែនដើមឈើជីវិតទេ។ គាត់ចង់មានន័យថា គ្មានវិធីដើម្បីឃើញតាមប្រវត្តិសាស្ត្រថា រចនាសម្ព័ន្ធពិតប្រាកដ គឺជាអ្វីនោះទេ។ លោកបណ្ឌិត ស្ទេវិន ជេ ហ្គោល (Stephen

Jay Gould) បាននិយាយថា យើងមិនគួរហៅវាថា ជាដើមឈើជីវិតនោះទេ ប៉ុន្តែជា «គុម្ពបន្លា» វិញ ព្រោះវាជាដើមដែលមានស្លឹកក្រាស់ពេក ដែលបាំងមែកទាំងអស់។ ដូច្នេះយើងមិនអាចមើលឃើញថា រចនាសម្ព័ន្ធនោះ ជាអ្វីទាល់តែសោះ។

ប៉ុន្តែសៀវភៅរៀននៅវិទ្យាល័យ នៅតែមានរូបភាពនៃដើមឈើជីវិតនៃវិវត្តន៍ ដូច្នេះមនុស្សគិតថា គំនូរទាំងនេះមានលក្ខណៈវិទ្យាសាស្ត្រ និងជាភស្តុតាងដែលជីវិតទាំងអស់កើតពីកោសិកាដើមរួម។ ប៉ុន្តែការពិត ភាពដូចគ្នា និងភាពខុសគ្នារវាងសត្វផ្សេងៗ នៅក្នុងបច្ចុប្បន្ន មិនអាចប្រាប់យើងអំពីអតីតកាលបានឡើយ។

ជាចុងក្រោយ សូមត្រឡប់ទៅគំនូរតូចរបស់លោកដាវីនដែលមានពាក្យថា «ខ្ញុំគិត» ៖



ដើមឈើជីវិតសព្វថ្ងៃមានភាពស្មុគស្មាញជាងគំនូររបស់លោក ដាវីន ហើយមានពណ៌ស្រស់ឆើតឆាយជាងផងដែរ។ ប៉ុន្តែដូចដើមឈើរបស់លោក ដាវីនដែរ ដើមឈើជីវិតសព្វថ្ងៃ គឺចេញពីការស្រមើស្រមៃរបស់អ្នកស្រាវជ្រាវ មិនមែនមកពីភស្តុតាងវិទ្យាសាស្ត្រទេ។ ដើមឈើនីមួយៗដែលយើងរកឃើញ នៅក្នុងសៀវភៅរៀនគួរតែមានពាក្យ «ខ្ញុំគិត» នៅក្បែរវាដែរ ព្រោះវាគ្រាន់តែជាការស្មានប៉ុណ្ណោះ ៖






# ៦

# លោក ដាវីនខុសអំពីកោសិកា និងជីវិត

នៅក្នុងរូបភាពខាងលើនេះ លោក ដាវីន កំពុងស្រមៃគិតពីកោសិកា។ គាត់សង្ឃឹមថា ជីវិតគឺសាមញ្ញណាស់ ហើយកោសិកានីមួយៗ គឺដូចដុំចាហួយតែប៉ុណ្ណោះ។

តើកោសិកាជាអ្វី? វត្ថុមានជីវិតទាំងអស់ ទាំងរុក្ខជាតិ សត្វ និងមនុស្ស ត្រូវបានផ្សំឡើងដោយអង្គភាពរចនាសម្ព័ន្ធ ដែលហៅថា កោសិកា។ វាតូចបំផុត ដែលយើងមិនអាចមើលឃើញដោយគ្មានមីក្រូទស្សន៍នោះទេ។

អ្នកវិទ្យាសាស្ត្រប៉ាន់ស្មានថា រាងកាយមនុស្សម្នាក់មានកោសិកាជាង ៣០,០០០,០០០,០០០,០០០ (៣០ ពាន់ពាន់លាន ឬ 30 trillion)! យើងមានកោសិកាស្បែក កោសិកាខួរក្បាល កោសិកាថ្លើម កោសិកាឈាម ។ល។



វិទ្យាសាស្ត្របច្ចុប្បន្នបានរកឃើញថា កោសិកានីមួយៗ ប្រៀបដូចជាទីក្រុងមួយដែលពេញដោយរោងចក្រដែលផលិតកម្លាំងថាមពល គីមី ប្រូតេអ៊ីន និងអ័រម៉ូនដែលមនុស្សត្រូវការដើម្បីរស់។ កោសិកាក៏មានបណ្ដាញព័ត៌មានដ៏ស្មុគស្មាញ ដែលប្រាប់គ្រប់រោងចក្រនៅក្នុងកោសិកា ពីរបៀបផលិតនូវអ្វីដែលវាត្រូវការ ហើយនៅពេលវាត្រូវផលិតរបស់នោះផង។ ប៉ុន្តែនៅសម័យរបស់លោក ដាវីន អ្នកវិទ្យាសាស្ត្រស្ទើរតែមិនដឹងអ្វីទាំងអស់អំពីកោសិកានោះទេ។

ហេតុអ្វីបានជាលោក ដារីនសង្ឃឹមថា កោសិកាមានលក្ខណៈសាមញ្ញ? ពីព្រោះគាត់ដឹងថា កោសិកាសាមញ្ញអាចកើតឡើងដោយចៃដន្យ ស្រួលជាងកោសិកាស្មុគស្មាញ។ សូមស្តាប់នូវអ្វីដែលលោក ដារីនបាននិយាយអំពីកោសិកា នៅក្នុងសំបុត្រមួយផ្ញើទៅកាន់លោក យ៉ូសែប ហូគើ (Joseph Hooker) ជាមិត្តរបស់គាត់។ គាត់កំពុងស្រមៃមើល ពីរបៀបដែលជីវិតអាចកើតឡើងដោយឯកឯង។ ដូច្នេះក្នុងសំបុត្រនេះ គាត់កំពុងនិយាយរបៀបស្រមើស្រមៃ មិនមែនរបៀបវិទ្យាសាស្ត្រទេ។ គាត់បានសរសេរថា «ប៉ុន្តែប្រសិនបើ – អូ ពាក្យ "ប្រសិនបើ" នោះធំណាស់! – ប្រសិនបើយើងអាច ស្រមៃ នៅក្នុងស្រះកក់ក្តៅតូចមួយ ដែលមានជាតិអាម៉ូញាក់ និងអំបិលផូស្វ័រគ្រប់ប្រភេទ ជាមួយនឹង ពន្លឺ កំដៅ និងអគ្គិសនី ។ល។ ដែលសមាសធាតុប្រូតេអ៊ីនមួយបានកើតឡើង ហើយរៀបនឹងផ្លាស់ប្តូរថែមទៀត កាន់តែស្មុគស្មាញទៅៗ...» លោក ដារីនកំពុងសង្ឃឹមថា កោសិកា គឺសាមញ្ញណាស់ ដែលវាអាចបង្កើតដោយខ្លួនឯងពីសារធាតុគីមីមួយចំនួន។



*សំបុត្រមួយពីលោកដាវីន ទៅលោក ហូគើ*
*(University of Cambridge Digital Library)*

ប៉ុន្តែឥឡូវនេះ ១៦០ឆ្នាំក្រោយមក យើងដឹងហើយថា ទស្សនៈអំពីកោសិកានេះ គឺគួរឲ្យអស់សំណើច។ កោសិកាមួយ គឺមានភាពស្មុគស្មាញ ដូចជាទីក្រុងមួយ។ តាមពិតទៅ យើងនៅមិនទាន់ដឹងទាំងស្រុងថា តើកោសិកាមានភាពស្មុគស្មាញ និងអស្ចារ្យប៉ុណ្ណានោះឡើយ។

នៅក្នុងសំបុត្ររបស់ លោក ដាវីន គាត់បាននិយាយអំពី «សមាសធាតុប្រូតេអ៊ីនមួយបានកើតឡើង ហើយរៀបនឹងផ្លាស់ប្តូរថែមទៀត កាន់តែស្មុគស្មាញទៅៗ»។ ប៉ុន្តែប្រសិនបើពិភពលោកទាំងមូលត្រូវបានផ្សំឡើងសុទ្ធតែប្រូតេអ៊ីន ហើយមហាសមុទ្រពោរពេញទៅដោយ

ប្រូតេអ៊ីនគ្រប់ប្រភេទ នោះការបង្កើតជីវិតដោយឯកឯងនៅតែមិនអាចទៅរួច។ ប្រូតេអ៊ីនមិនមែនជាមូលដ្ឋាននៃជីវិតទេ។ ឥឡូវនេះយើងដឹងហើយថា ជីវិតតម្រូវឲ្យមានការរៀបចំឡើងយ៉ាងស្មុគស្មាញនូវម៉ូលេគុលសរីរាង្គជាក់លាក់ ព្រមទាំងកូដកម្មវិធីដូចនៅក្នុងកុំព្យូទ័រ។

កោសិកាតែមួយអាចប្រៀបធៀបទៅនឹងទីក្រុងមួយ ហើយប្រព័ន្ធព័ត៌មានរបស់កោសិកា គឺអាចប្រៀបធៀបទៅនឹងអ៊ីនធឺណិត ហើយប្រព័ន្ធថាមពលរបស់កោសិកា គឺដូចជាបណ្តាញថាមពលរបស់ទីក្រុង។ មិនត្រឹមតែប៉ុណ្ណោះ ការរចនាមេកានិកនៃកោសិកាអនុញ្ញាតឲ្យវាបំបែកកោសិកាជាពីរក្នុងរយៈពេលត្រឹមតែ២០នាទីប៉ុណ្ណោះ! (ចូរស្រមៃការចម្លងទីក្រុងមួយ ឬរោងចក្រមួយក្នុងរយៈពេលត្រឹមតែ ២០ នាទីប៉ុណ្ណោះ!)

នៅទំព័របន្ទាប់ យើងឃើញរូបនៃកោសិកាមួយដែលត្រូវបានកាត់ជាពីរ ដើម្បីមើលឃើញខាងក្នុង។ អ្នកអាចឃើញថា វាពិតជាមិនមែនជាដុំចាហួយនោះទេ៖



*Copyright Russell Kightley. Used with Permission*

រូបនេះបង្ហាញលម្អិតបំផុតពីកោសិកា។ លោក ដាវីន សង្ឃឹមថា
កោសិកាគឺសាមញ្ញណាស់ ប៉ុន្តែឥឡូវនេះយើងដឹងថាវាស្មុគស្មាញ
ដូចទីក្រុងមួយវិញ។

លោក ដារីនបានបង្កើតឧបសគ្គដ៏ល្បីមួយនៅក្នុងសៀវភៅរបស់គាត់ឈ្មោះ «ប្រភពដើមនៃប្រភេទសត្វ» *(The Origin of Species)*។ គាត់ថា «ប្រសិនបើមនុស្សណាអាចបង្ហាញថា មានសរីរាង្គស្មុគស្មាញណាមួយ ដែលមិនអាចកើតឡើងដោយការផ្លាស់ប្តូរបន្តិចម្តងៗ ជាបន្តបន្ទាប់ នោះទ្រឹស្តីរបស់ខ្ញុំនឹងដួលជាមិនខាន។ ប៉ុន្តែខ្ញុំរកមិនឃើញករណីបែបនេះទេ»។

ហេតុអ្វីបានជាគាត់រកមិនឃើញករណីបែបនេះ? ដោយសារតែគាត់រស់នៅមុនសម័យដែលគេហៅថា «បដិវត្តន៍ជីវសាស្ត្រ»។ គាត់មិនដឹងអ្វីទាំងអស់អំពីជីវសាស្ត្រទំនើប។ ប្រសិនបើលោក ដារីន មើលសៀវភៅជីវសាស្ត្រនៃថ្នាក់វិទ្យាល័យសព្វថ្ងៃ គាត់នឹងមិនអាចយល់អ្វីសោះ។ បើគាត់បើកទស្សនាវដ្ដីវិទ្យាសាស្ត្រទំនើបសព្វថ្ងៃនេះ គាត់នឹងមិនយល់ សូម្បីតែប្រយោគខ្លីមួយ។ គាត់មិនដឹងអ្វីទាំងអស់អំពី...

ជីវសាស្ត្រកោសិកា
ជីវគីមី
ជីវសាស្ត្រម៉ូលេគុល
ហ្សែន Mendelian
ឌីអិនអេ (DNA)

ការផ្លាស់ប្តូរនៃហ្សែន (Mutations)
កូដហ្សែន
ពន្ធុវិទ្យា
ពន្ធុវិទ្យាប្រជាជន
ប្រព័ន្ធព័ត៌មានជីវសាស្ត្រ
សរសៃប្រសាទ
និងវិទ្យាសាស្ត្រចំនួន ១០០ ផ្សេងទៀត។

ជាថ្មីម្តងទៀត ដើម្បីឲ្យយុត្តិធម៌ គ្មាននរណាម្នាក់ក្នុងសម័យលោក ដាវីនដែលដឹងរឿងទាំងនេះទេ។ ប៉ុន្តែយើងត្រូវតែយល់អំពីចំណុចនេះមួយ៖ សម្រាប់ លោក ដាវីន ជីវិតគឺជាអ្វីមួយដែលអាចពន្យល់បានយ៉ាងងាយស្រួល គឺជាសារធាតុមួយដែលអាចផ្លាស់ប្តូរបានបន្តិចម្តងៗ ហើយអាចប្រែរូបរាងទៅតាមកាលៈទេសៈ។

## កុំព្យូទ័រនៅក្នុងកោសិកា

លោក ដាវីនមិនអាចគិតស្មានថា គ្រប់កោសិកាទាំងអស់មានប្រព័ន្ធព័ត៌មានដ៏ស្មុគស្មាញបំផុត ដែលយើងអាចប្រៀបប្រដូចទៅ នឹងប្រព័ន្ធអ៊ីនធឺណិត។ មិនត្រឹមតែប៉ុណ្ណឹងទេ នៅកណ្តាលកោសិកានីមួយៗ (មិនថា រុក្ខជាតិ សត្វ ឬមនុស្ស) មានឧបករណ៍រក្សាទុកព័ត៌មានមួយដែលមុខងារស្រដៀងនឹងមេមូរីហាដដ្រាយ (hard drive)

នៅក្នុងកុំព្យូទ័រ។ កុំព្យូទ័រដែលយើងប្រើប្រាស់រាល់ថ្ងៃនៅក្នុងផ្ទះ និង ការិយាល័យ សុទ្ធតែមាន ហាដដ្រាយ (ឬមេម៉ូរី) សម្រាប់រក្សាទុកឯកសារ ព័ត៌មាន និងកម្មវិធីផ្សេងៗ។ ដូចគ្នានេះដែរ គ្រប់កោសិកាក៏មានមេម៉ូរីដែរ ដែលប្រព័ន្ធរបស់វាគេហៅថា ឌីអិនអេ (DNA)។ ប៉ុន្តែការមានមេម៉ូរី ឬហាដដ្រាយ ក្នុងកុំព្យូទ័រ ឬទូរស័ព្ទ គឺមិនគ្រប់គ្រាន់ទេ។ ប្រសិនបើ មេម៉ូរីឬហាដដ្រាយនោះមិនមានកម្មវិធី ឬកូដ (software) ដែលផ្ទុកនៅក្នុងវា នោះមេម៉ូរីនោះគ្មានប្រយោជន៍ ហើយកុំព្យូទ័រឬទូរស័ព្ទរបស់យើង នឹងមិនដំណើរការទេ។ យើងត្រូវតែដំឡើងកម្មវិធីទៅលើហាដដ្រាយ ព្រោះគឺកម្មវិធីនៅលើហាដដ្រាយដែលធ្វើឲ្យកុំព្យូទ័ររបស់យើងដំណើរការបាន។

រីឯកោសិកាក៏ដូចគ្នាដែរ។ ប្រសិនបើហាដដ្រាយរបស់កោសិកា (ហៅថា ឌីអិនអេ DNA) មិនបានផ្ទុកព័ត៌មាន (កូដ) ដែលប្រាប់កោសិកា នូវអ្វីដែលត្រូវធ្វើ នោះកោសិកាមិនអាចមានដំណើរការបានសោះ។ ដូច្នេះព្រះជាម្ចាស់បានផ្ទុកទៅលើឌីអិនអេ នៃភាវៈមានជីវិត នូវកម្មវិធី (កូដ) ដ៏អស្ចារ្យ ដែលហៅថា ហ្សែនណូម (genome)។ វាជាកូដដែលស្មុគស្មាញ និងអស្ចារ្យជាង

កម្មវិធីកូដនៅលើកុំព្យូទ័ររបស់យើងទៅទៀត! កម្មវិធីនេះដែលយើងហៅថា ហ្សែនណូម ប្រាប់កោសិកាពី**ការ**ដែលត្រូវធ្វើ និង**របៀប**ធ្វើការនោះ ហើយនិង**ពេល**ដែលត្រូវធ្វើ។ ហ្សែនណូមក៏មានព័ត៌មានទាំងអស់អំពីលក្ខណៈរាងកាយនៃសារពាង្គកាយផងដែរ។ ឧទាហរណ៍ ហ្សែនណូមរបស់មនុស្សមានផ្ទុកព័ត៌មាន និងការណែនាំទាំងអស់ដែលកំណត់ថា បុគ្គលមានលក្ខណៈយ៉ាងណា  ទាំងពណ៌សក់របស់អ្នក កម្ពស់ សម្បុរស្បែក ទំហំច្រមុះ ។ល។





***រូបឌីអិនអេ (**DNA)។ នៅពេល ឌីអិនអេ ដែលនៅក្នុងកោសិកានីមួយៗរបស់អ្នកត្រូវបានលាតសន្ធឹង វាមើលទៅដូចជាជណ្ដើរដែលត្រូវបានរមួល។ ជណ្ដើរ ឌីអិនអេ នៅក្នុងកោសិកាមនុស្សមានប្រវែងពីរម៉ែត្រ នៅពេលដែលវាលាតសន្ធឹង ហើយមានអក្សរកូដ ៣ ពាន់លានតួ។ កូដនេះគឺស្ថិតនៅលើ «កាំ» ជណ្ដើរ។ កាំនីមួយៗមានអក្សរពីរតួ។*

ហ្សែនណូម (genome) អាចប្រៀបធៀបដូចជាសៀវភៅមួយដែរ។ សៀវភៅត្រូវបានបែងចែកជាជំពូកៗ។

ដូចគ្នាដែរ ហ្សែនណូមត្រូវបានបែងចែកជាផ្នែកៗដែលហៅថា ក្រូម៉ូសូម (chromosome)។ គ្រប់កោសិការបស់មនុស្ស មាន២៣ក្រូម៉ូសូម ជាមួយគ្នា (៤៦ ទាំងអស់)។ ក្រូម៉ូសូមនីមួយៗត្រូវបានបែងចែកទៅជាផ្នែកតូចៗទៀត ហៅថា ហ្សែន (gene)។ ហ្សែនផ្ទុកនូវព័ត៌មាន ដែលកោសិកាត្រូវការ ដើម្បីបង្កើតប្រូតេអ៊ីនដ៏ស្មុគស្មាញ ដើម្បីយើងអាចរស់នៅបាន។ ហ្សែននីមួយៗត្រូវបានផ្សំឡើងដោយ«ពាក្យ»បីតួ រាប់ពាន់ ដែលហៅថា កូដុន (codon) ហើយ កូដុន ត្រូវបានផ្សំឡើងដោយ«តួអក្សរ» ដែលហៅថា នុយក្លេអូទីត (nucleotide)។ ដូច្នេះហ្សែនណូមប្រៀបដូចជាសៀវភៅនេះដែរ។ វាមានជំពូក (ក្រូម៉ូសូម) ប្រយោគវែងៗ (ហ្សែន) ពាក្យ (កូដុន) និងតួអក្សរ (នុយក្លេអូទីត)។

ដូចដែលខ្ញុំបាននិយាយ ការណែនាំនៅក្នុងហ្សែនណូម អាចប្រៀបធៀបទៅនឹងការណែនាំនៅក្នុងកូដកុំព្យូទ័រ។ ខាងក្រោម គឺជាគេហទំព័រយ៉ាងសាមញ្ញ ដែលយើងភាគច្រើនបានស្គាល់ហើយ គឺគេហទំព័រស្វែងរករបស់ Google៖




ទោះបីជាគេហទំព័រនេះមានលក្ខណៈសាមញ្ញក៏ដោយ វិស្វករនៅក្រុមហ៊ុន Google ត្រូវសរសេរកូដចំនួន៦៧ទំព័រ (គឺ ១៣០ ០០០ អក្សរ) ដើម្បីឲ្យគេហទំព័រនេះមានរូបរាងត្រឹមត្រូវ និងធ្វើការងារត្រឹមត្រូវដែរ។ ខាងក្រោមនេះជាកូដមួយទំព័រក្នុងចំណោម ៦៧ទំព័រនោះ។

```
<!doctype html><html itemscope="" itemtype="http://schema.org/WebPage"
lang="km"><head><meta charset="UTF-8"><meta content="origin" name="referrer"><meta
content="/images/branding/googleg/1x/googleg_standard_color_128dp.png"
itemprop="image"><link href="/manifest?pwa=webhp" crossorigin="use-credentials"
rel="manifest"><title>Google</title><script
nonce="uHLiPOyVDprrTZUuT9L88g">(function(){window.google={kEI:'tc-
SY5_nJ8mt0PEP9YeAyAs',kEXPI:'31',u:'cbf56c76',kBL:'oABN'};google.sn='webhp';google.k
HL='km';})();(function(){

var f=this||self;var h,k=[];function l(a){for(var b;a&&(!a.getAttribute||!
(b=a.getAttribute("eid")));)a=a.parentNode;return b||h}function m(a){for(var b=null;a&&(!
a.getAttribute||!(b=a.getAttribute("leid")));)a=a.parentNode;return b}

function n(a,b,c,d,g){var e="";c||-1!==b.search("&ei=")||
(e="&ei="+l(d),-1===b.search("&lei=")&&(d=m(d))&&(e+="&lei="+d));d="";!
c&&f._cshid&&-1===b.search("&cshid=")&&"slh"!==a&&(d="&cshid="+f._cshid);c=c||"/"+
(g||"gen_204")+"?atyp=i&ct="+a+"&cad="+b+e+"&zx="+Date.now()+d;/^http:/
i.test(c)&&"https:"===window.location.protocol&&(google.ml&&google.ml(Error("a"),!1,
{src:c,glmm:1}),c="");return
c};h=google.kEI;google.getEI=l;google.getLEI=m;google.ml=function(){return
null};google.log=function(a,b,c,d,g){if(c=n(a,b,c,d,g)){a=new Image;var
e=k.length;k[e]=a;a.onerror=a.onload=a.onabort=function(){delete
k[e]};a.src=c}};google.logUrl=n;}).call(this);(function()
{google.y={};google.sy=[];google.x=function(a,b){if(a)var c=a.id;else{do
```

តើអ្នកអាចអានកូដនេះបានទេ? ប្រហែលជាអានមិនបានទេ។ អ្នកឃើញថា ទំព័រនេះពេញដោយអក្សរ និងលេខ និងនិមិត្តសញ្ញាដែលពិបាកអានណាស់។ មើលទៅដូចជាគ្មានន័យអ្វីទាំងអស់។ ប៉ុន្តែអក្សរចម្លែកទាំងនោះសុទ្ធតែមានគោលបំណងសំខាន់សម្រាប់គេហទំព័រ Google។ កូដនេះមានសេចក្ដីណែនាំលម្អិត ដោយប្រើភាសាពិសេសមួយហៅថា កូដ HTML។ បើគ្មានការណែនាំទាំងនេះទេ គេហទំព័រ Google នឹងមិនដំណើរការបានឡើយ។

ប្រសិនបើអក្សរតែមួយ ឬពីរតួនៅក្នុងកូដនេះ ត្រូវបានផ្លាស់ប្ដូរ ឬបាត់បង់ដោយចៃដន្យ គេហទំព័រ Google Search ប្រហែលជាមានរូបរាងមិនត្រឹមត្រូវ ហើយប្រហែលជាមិនអាចធ្វើការងារដែលវាត្រូវធ្វើនោះទេ។ ប្រសិនបើ៤ ឬ ៥បន្ទាត់នៃកូដនេះត្រូវបានលុបចេញ នោះគេហទំព័រ Google នឹងមិនដំណើរការទេ។

រីឯ ហ្សែនណូមក្នុងកោសិកា វាដូចគ្នាដែរ។ ប្រសិនបើកូដមួយចំនួននៅក្នុងហ្សែនណូម ត្រូវបានបាត់បង់ ឬផ្លាស់ប្ដូរ ដោយចៃដន្យ (គេហៅថា mutation) ការផ្លាស់ប្ដូរនោះមុខជាមានផលវិបាកដល់សារពាង្គកាយ។

ប្រសិនបើហ្សែនមួយត្រូវបានបាត់បង់ នោះផលអវិជ្ជមាន គឺធំសម្បើមណាស់។

យើងនឹងនិយាយបន្ថែមទៀតអំពីហ្សែនណូម នៅក្នុងជំពូកបន្ទាប់ ប៉ុន្តែចំណុចដែលខ្ញុំចង់បង្ហាញនៅក្នុងជំពូកនេះគឺថា **លោក ដាវីន មិនដឹងសោះថា កោសិកាស្មុគស្មាញប៉ុណ្ណានោះទេ។** គាត់គិតថា វាជាដុំចាហួយមួយ ប៉ុន្តែផ្ទុយទៅវិញ វាដូចជាទីក្រុងមួយ ដែលពោរពេញទៅដោយរោងចក្រ ម៉ាស៊ីនយន្ត និងបណ្ដាញព័ត៌មាន។

ទីបំផុត នេះគឺជារឿងមួយដែលបង្ហាញយ៉ាងច្បាស់អំពីលោក ដាវីន។ នៅឆ្នាំ១៨៦០ គាត់បានសរសេរសំបុត្រទៅមិត្តរបស់គាត់ឈ្មោះ អេសា គ្រេ (Asa Gray) ថា «នៅពេលណាដែលខ្ញុំសម្លឹងមើលស្លាបនៅកន្ទុយក្ងោក ធ្វើឲ្យខ្ញុំឈឺ [ចង់ក្អួត]»។



ហេតុអ្វីបានជាស្លាបដ៏ស្រស់ស្អាតនោះធ្វើឲ្យគាត់ចង់ក្អួត? ដោយសារតែគាត់ មិនអាចពន្យល់ពីភាពស្រស់ស្អាត និងភាពស្មុគស្មាញរបស់វាបានឡើយ។ លោក ដាវីនគឺជាមនុស្សដែលមានទុក្ខ។ លោក អេឌ្រាន ដិសមុន (Adrian Desmond) និង ជែម មូរ (James Moore) បាននិពន្ធ ជីវប្រវត្តិអំពី លោក ដាវីន ដែលមានចំណងជើងថា «ជីវិតរងទុក្ខរបស់អ្នកវិវត្តន៍»។ សៀវភៅនោះបានបង្ហាញយ៉ាងច្បាស់ថា លោក ដាវីនបានចំណាយពេលស្ទើរតែពេញជីវិតរបស់គាត់ ដោយការញ័រ និងក្អួតជារៀងរាល់ថ្ងៃ។ វាមិនមែន មកពីជំងឺត្រូពិចមួយនោះទេ។ គាត់ស្ថិតក្នុងភាពចលាចលខាងវិញ្ញាណ និងផ្លូវចិត្ត។ ដូច្នេះគាត់ក៏បានឈឺគ្រប់ពេលដែលគាត់មើលស្លាបដ៏ស្រស់ស្អាត ព្រោះគាត់មិនអាចពន្យល់វាដោយការច្នៃដន្យនៃវិវត្តន៍បានឡើយ។ ភាពស្មុគស្មាញនៃអ្វីមួយ ដូចរោមស្លាបធ្វើឲ្យខូចទស្សនៈរបស់គាត់។ ស្តាយណាស់! នៅពេលអ្នក និងខ្ញុំមើលស្លាបក្ងោក ឬវត្ថុដ៏ស្រស់ស្អាតផ្សេងទៀត យើងដឹងដោយស្វ័យប្រវត្តិនូវអត្ថន័យរបស់វា៖ គឺវាត្រូវបានរចនាឡើងដោយព្រះជាម្ចាស់!



# ៧

# លោក ដាវីនខុសអំពីជម្រើសដោយធម្មជាតិ (ការសំរាំងដោយធម្មជាតិ)

ពិបាកជឿថា លោក ដាវីនខុសអំពីជម្រើសដោយធម្មជាតិ ព្រោះការនោះជាទ្រឹស្ដីដែលធ្វើឲ្យគាត់ល្បី។ ប៉ុន្តែ មុននឹងយើងនិយាយអំពីជម្រើសដោយធម្មជាតិ យើងត្រូវរំឭកខ្លួនអំពីការដែលយើងបានរៀននៅជំពូកមុន៖ ក្នុងកោសិកានៃរុក្ខជាតិ សត្វ និងមនុស្សនីមួយៗ មានឌីអិនអេ (DNA) ដែលយើងបានប្រៀបធៀបទៅនឹងហាដដ្រាយ (មេមូរី hard drive) នៅក្នុងកុំព្យូទ័រ។ ព័ត៌មាន ឬកម្មវិធីនៅលើឌីអិនអេនោះ ត្រូវបានគេហៅថា ហ្សែនណូម (genome)។  ហ្សែនណូម គឺជាកូដដ៏វែងដែលត្រូវបានសរសេរនៅលើឌីអិនអេ។ ហ្សែនណូមនោះ

ប្រាប់កោសិកានូវអ្វីដែលត្រូវធ្វើ និងរបៀបធ្វើ។ វាប្រៀប ដូចជាកូដកម្មវិធីដែលវិស្វករបង្កើតសម្រាប់គេហទំព័រ ដែលប្រាប់កុំព្យូទ័រ ឬទូរស័ព្ទរបស់យើងថា គេហទំព័រនោះ គួរមើលបែបណា និងដំណើរការបែបណា។ សូមចាំថា កូដសម្រាប់គេហទំព័រ Google Search មាន ១៣០,០០០ អក្សរ (៦៧ទំព័រ)! ប៉ុន្តែលេខកូដនៅលើ ឌីអិនអេរបស់មនុស្សមាន ៣,០០០,០០០,០០០ អក្សរ (៣ ពាន់លាន)!  ប្រសិនបើអ្នកចង់ព្រីនកូដ ៣ពាន់លានអក្សរ នោះ អ្នកត្រូវការក្រដាស ១,៥០០,០០០ សន្លឹក។ (ជង់ ក្រដាសនោះនឹងមានកម្ពស់ស្មើនឹងអគារ ១៦ ជាន់!) ប៉ុន្តែ ព័ត៌មានទាំងអស់នោះមាននៅក្នុងកោសិកាទាំងអស់របស់ មនុស្សយើង (ទាំង៣០,០០០,០០០,០០០,០០០កោសិកា) គឺកោសិកាដែលយើងមើលមិនឃើញ! អស្ចារ្យមែន!

## ការផ្លាស់ប្តូរព័ត៌មានហ្សែនដោយចៃដន្យ

រាល់ពេលដែលកោសិកាមួយនៅក្នុងខ្លួនរបស់យើងបំបែក ជាពីរ ដើម្បីបង្កើតកោសិកាថ្មី នោះព័ត៌មានទាំងអស់នៃ ហ្សែនណូម (ទាំង៣ពាន់លានតួអក្សរ) ក៏ចម្លងខ្លួនទៅក្នុង កោសិកាថ្មីដែរ! ប៉ុន្តែរាល់ពេលដែលវាបំបែកនិងចម្លង ដូច្នេះ មានកំហុសមួយចំនួនដែលបានចូលទៅក្នុង

ហ្សែនណូមថ្មីដោយចៃដន្យ។ អ្នកវិទ្យាសាស្ត្រហៅកំហុសទាំងនេះថា ការផ្លាស់ប្តូរ (mutation)។

ការផ្លាស់ប្តូរនេះប្រៀបនឹងកំហុសអក្ខរាវិរុទ្ធដែលយើងបានធ្វើដោយចៃដន្យ ពេលណាយើងវាយបញ្ចូលឯកសារចូលទៅក្នុងកុំព្យូទ័រ ឬផ្ញើសារនៅលើទូរស័ព្ទរបស់យើង។ តាមពិតទៅ រាល់ពេលដែលកោសិកាមួយនៅក្នុងខ្លួនរបស់យើងបំបែក ដើម្បីបង្កើតជាកោសិកាថ្មី ប្រហែលកំហុសថ្មីចំនួន ៣០០ បានចូលទៅក្នុងហ្សែននៃកោសិកាថ្មីនោះដោយចៃដន្យ។ តាមពិតទៅ ៣០០កំហុស ក្នុងកូដ ៣ ពាន់លានតួ គឺមិនច្រើនប៉ុន្មានទេ ប៉ុន្តែកំហុសស្ទើរតែទាំងអស់នោះធ្វើឲ្យកោសិកាចុះខ្សោយបន្តិច។

ចាប់តាំងពីឆ្នាំ ១៩០០ នៅពេលដែលអ្នកវិទ្យាសាស្ត្របានរកឃើញការផ្លាស់ប្តូរនេះ ពួកគេសង្ឃឹមថា ការផ្លាស់ប្តូរដោយចៃដន្យទាំងនេះ អាចគាំទ្រ ទ្រឹស្តីរបស់លោកដាវីន ដែលថា សត្វសាមញ្ញអាចផ្លាស់ប្តូរទៅជាសត្វដ៏ស្មុគស្មាញបន្តិចម្តងៗ ក្នុងរយៈពេលរាប់លានឆ្នាំ(ការវិវត្តន៍)។ ពួកគេសង្ឃឹមថា ការផ្លាស់ប្តូរដោយចៃដន្យមួយចំនួនអាចមានប្រយោជន៍ដល់សត្វ ពោលគឺជួយសត្វនោះឲ្យទទួលបានសមត្ថភាពថ្មីដែលមានប្រយោជន៍។ ពួកគេបាន

គិតថា ក្នុងរយៈពេលរាប់លានឆ្នាំ ការកែលម្អដោយចៃដន្យតូចៗទាំងអស់នោះ អាចប្រមូលផ្តុំដើម្បីបង្កើតប្រភេទសត្វថ្មីទាំងស្រុង។ ប្រហែលជាត្រី អាចប្រែក្លាយទៅជាសត្វល្មូនដោយការផ្លាស់ប្តូរតូចៗរាប់លាននៅក្នុងហ្សែនណូមរបស់ត្រីនោះ។

## ជម្រើសដោយធម្មជាតិ (ការសំរាំងដោយធម្មជាតិ)

តើជម្រើសដោយធម្មជាតិគឺជាអ្វី? យើងទាំងអស់គ្នាធ្លាប់ស្គាល់ការសំរាំងនៃមនុស្ស(ការជ្រើសរើសពូជដ៏ល្អ)។ ឧទាហរណ៍ កសិករម្នាក់សម្គាល់ឃើញថា មាន់ខ្លះមានសុខភាពល្អ និងលូតលាស់លឿនជាង តែខ្លះទៀតខ្សោយជាង។ ដូច្នេះគាត់បន្តសំរាំងមាន់ដែលមានសុខភាពល្អសម្រាប់បង្កាត់ពូជ។ មិនយូរប៉ុន្មាន មាន់ភាគច្រើននៅក្នុងកសិដ្ឋាន មានសុខភាពល្អជាង ហើយកូនច្រើនជាង។ កសិករបានសំរាំងយកពូជដែលមានសុខភាពល្អ ហើយ**មិន**ជ្រើសរើសពូជខ្សោយទេ។ នេះគឺជាការសំរាំងរបស់មនុស្ស។

ការសំរាំងដោយធម្មជាតិ (ជម្រើសដោយធម្មជាតិ) គឺស្រដៀងគ្នា ប៉ុន្តែជំនួសឲ្យកសិករឆ្លាតវៃ ជ្រើសរើសសត្វដែលមានសម្បទាល្អសម្រាប់បន្តពូជ ហើយមិនជ្រើស

រើសសត្វដែលមានសម្បទាខ្សោយ គឺ**ធម្មជាតិ**ដែលធ្វើការជ្រើសរើស និងការបដិសេធវិញ។ ប៉ុន្តែមានបញ្ហា គឺធម្មជាតិមិនមានខួរក្បាល ហើយមិនចេះជ្រើសរើសទេ។ អ៊ីចឹង ធ្វើដូចម្ដេចឲ្យធម្មជាតិអាចជ្រើសរើសបាន បើគ្មានមនុស្សជួយសម្រេចចិត្ត? ការពិតធម្មជាតិមិនអាចធ្វើការជ្រើសរើស និងការសំរាំងសោះ។ ជម្រើសនៃធម្មជាតិគ្រាន់តែមានន័យថា សត្វដែលមានសម្បទាល្អ វានឹងរស់រានមានជីវិត និងមានកូនចៅកាន់តែច្រើន តែសត្វដែលមានសម្បទាខ្សោយ នឹងមានកូនចៅតិចជាង រហូតដល់ពួកវាដាច់ពូជទៅ។

ដូច្នេះពាក្យដែលល្អជាង សម្រាប់ជម្រើសដោយធម្មជាតិគឺ «ការបន្តពូជតាមកម្រិតខ្ពស់ និងកម្រិតទាប» ពោលគឺ សត្វដែលខ្លាំងអាចបន្តពូជច្រើនជាង សត្វដែលខ្សោយ។ តើពាក្យ «ជម្រើសដោយធម្មជាតិ»គ្រាន់តែមានន័យអ៊ីចឹងឬ? បាទ។ ជម្រើសដោយធម្មជាតិមានន័យសាមញ្ញថា បើសរីរាង្គខ្សោយ វានឹងមិនបន្តពូជបានច្រើនទេ ប៉ុន្តែបើវាល្អ វានឹងបង្កើតកូនបានច្រើនជាងធម្មតា។ ពេលយើងពន្យល់ដោយរបៀបសាមញ្ញនេះ ជម្រើសដោយធម្មជាតិ មិនមែនជាអ្វីអស្ចារ្យទេ។

## តើសត្វអាចសម្របខ្លួន
